# ការបន្តពូជនៃដំណាំហូបផ្លែ

## ១-គ្រាប់

### ១.១ លក្ខណៈទូទៅ

ជាវិធីមួយ ដែលមានលក្ខណៈងាយស្រួលអាចមានលទ្ធភាព និង ទទួលបាននូវរុក្ខជាតិក្រោយៗទៀត មានគុណភាពល្អ ជៀសវាងពីជំងឺផ្សេងៗ ធន់នឹងលក្ខខណ្ឌអាកាសធាតុ បង្កើតប្រព័ន្ធឫសល្អ ធន់នឹងដីអត់ជីវជាតិ មានលក្ខណៈខុសប្លែកពីមេបាដោយសារក្លាយជាមួយរុក្ខជាតិពូជផ្សេងទៀត ។

### ១.២ គោលបំនង

-បង្កើតពូជថ្មី

-ប្រើប្រាស់ជាជើងទំរ

## ២-សរីរាង្គរបស់ដើម :

### ២.១ លក្ខណៈទូទៅ :

មានលទ្ធភាពរក្សាជំងឺដែលមាននៅលើមេបា មានលក្ខណៈពុំសូវមាំទាំ អាយុខ្លី ប្រព័ន្ធឫសខ្សោយ ពុំមានលទ្ធភាពចាក់ចូលក្នុងដីបានជ្រៅ ។

### ២.២ គោលបំនង :

-ដើម្បីអោយឆាប់មានផ្លែ

-រក្សាលក្ខណៈរុក្ខជាតិជំនាន់ក្រោយអោយដូចរុក្ខជាតិមេបា

## ៣-ការបំប៉ោដំណាំហូបផ្លែ

ជាការភ្ជាប់ផ្នែកផ្សេងៗរបស់រុក្ខជាតិដូចជាមែក ពន្លក ដែលហៅថា ***ខ្នែងបំប៉ៅ ឬ ពន្លកបំប៉ៅ*** ទៅលើរុក្ខជាតិមួយប្រភេទទៀតដែលហៅថា ***ជើងទំរ*** តែឋិតនៅក្នុងគ្រួសារតែមួយ ។

### ៣.១ ការជ្រើសរើសខ្នែងបំប៉ោ :

-ផ្តល់ផ្លែច្រើន

-ផ្លែមានឱជារស់ផ្អែមឆ្ងាញ់

-ធន់នឹងជំងឺ

-ធន់នឹងសត្វល្អិត

### ៣.២ ការជ្រើសរើសដើមទំរ :

-អាយុ ៨-៣៦ ខែ កើតចេញពីគ្រាប់

-មានការលូតលាស់ល្អ

-មានប្រព័ន្ធឬសល្អ

-ធន់នឹងការរាំងស្ងួត និង លិចទឹក

-ធន់នឹងការខ្វះជីជាតិ

-ពុំមានការវាតត្បាតពីសត្វល្អិត និង ជំងឺ

-អង្កត់ផ្ចិតត្រូវស្មើ ឬ ធំជាងអង្កត់ផ្ចិតរបស់ខ្នែងបំបៅ

### ៣.៣ ដំណាក់កាលនៃការបំបៅ :

-ការរៀបចំដើមទំរ

-ការរៀបចំខ្នែងបំបៅ ឬ ពន្លកបំបៅ

-ការភ្ជាប់ខ្នែងបំបៅ ឬពន្លកបំបៅទៅដើមទំរ

-ការពិនិត្យតាមដាន និង ថែទាំ

### ៣.៤ កាយវិភាគនៃដំណាំហូបផ្លែ :

-ស្រទាប់សំបក (Ecorce) ដែលមានពណ៌ត្នោត ឬ បៃតង :

+ទន់ មានទឹកដម ឋិតនៅលើមែកតូចៗ

+ស្ងួត រឹង ឋិតនៅលើមែកចាស់

+មានតួនាទីដឹកនាំរុក្ខរស់ចូលទៅស្រទាប់ Bois

-ស្រទាប់កុំប៊ីយ៉ូម និង សាច់ឈើស្រាយមានរាងថ្លាជាងស្រទាប់សំបក ស្រទាប់នេះស្ថិតនៅចន្លោះរវាងសំបកនិង សាច់ឈើខាងក្នុងមានពណ៌ចំរុះ

-នៅចន្លោះសំបក និង សាច់ឈើខាងក្នុង មានកុំប៊ីយ៉ូម ជាផ្នែកដែលផលិតសាច់ឈើនៅខាងក្នុង និង សំបកនៅ ខាងក្រៅ

-សាច់ឈើស្រាយជាផ្នែកខាងក្រៅនៃសាច់ឈើខាងក្នុង មានទឹកច្រើននិងសើមជាងផ្នែកកណ្តាលនៃសាច់ឈើ ធ្វើចរាចររុក្ខរស់ចុះទៅក្រោមតាមសរសៃនៃសំបក

### ៣.៥ ទីតាំងនៃដើមទំរ និង ខ្នែងបំបៅ :

ការចោះ លាក់ស្រទាប់កុំប៊ីយ៉ូម នៅលើដើមទំរ និង ខ្នែងបំបៅ គឺជាបញ្ហាសំខាន់បំផុតដើម្បីទទួលលទ្ធផលល្អ ត្រូវដាក់ស្រទាប់កុំប៊ីយ៉ូម សំបក និង សាច់ឈើ នៃដើមទំរ និង ខ្នែងបំបៅ ឬ ពន្លកបំបៅអោយត្រួតស៊ីគ្នាតាមស្រទ

និមួយៗ ។




រូបភាពទី ២- ស្រទាប់ផ្សេងៗនៃដើមរុក្ខជាតិ




រូបភាពទី៣-ទីតាំងនៃស្រទាប់នីមួយៗរបស់ដើមទំរ និង ខ្នែងផ្ស




**រូបភាពទី៤-ទីតាំងនៃស្រទាប់នីមួយៗរបស់ដើមទំរ និង ខ្នែងផ្សាំ**

**៣.៦ ពេលវេលាដែលត្រូវធ្វើការបំបៅ :**

-នៅរដូវភ្លៀង Cambium មានសកម្មភាពខ្លាំង

-សីតុណ្ហភាព ២៣-២៦ អង្សាសេ រុក្ខជាតិសំបូរជាតិជ័រ

**៣.៧ ប្រភេទនៃការបំបៅ :**

**៣.៧.១ ការបំបៅដោយភ្នែក :**

**៣.៧.១.១-ការបំបៅតាម Forkert :**

-ដើមទំរមានអាយុ ១ ឆ្នាំ អង្កត់ផ្ចិត ១៣-១៦ ស.ម

-កំពស់ពីផ្ទៃដី ៣០-៤០ ស.ម

-បង្អួច :បណ្តោយ ២,៥-៣ ស.ម និង ទទឹង ១-១,៥ ស.ម

-ទំហំភ្នែកបំបៅ ប៉ុន ឬ តូចជាងទំហំបង្អួចរបស់ដើមទំរ

-រួចផ្ទិបភ្ជាប់ទៅនឹងបង្អួច បន្ទាប់មករុំនឹងបង់ប្លាស្ទិចអោយជិត

-ទុករយៈពេល ១៥ ថ្ងៃ រួចស្រាយពិនិត្យមើលភ្នែកពន្លក

-បើនៅពណ៌បៃតងមានន័យថារស់ ត្រូវរុំសារជាថ្មីដោយទុកចន្លោះកន្លែងភ្នែក ពន្លក



ការជៀវសំបកដែលច្រៀក

១-ជៀវសំបកជាបង្អួចលើដើមទំរ ៤- រុំបង់ប្លាស្ទិចអោយជិតល្អ

២-ចៀវភ្នែកបំបៅ ៥-ភ្នែកបំបៅចាប់ផ្ដើមដុះ

៣-ដាក់ភ្នែកផ្សាំនៅក្នុងបង្អួច ៦-ភ្នែកបំបៅលូតលាស់ និងកាត់ចុងដើមទំរចោល

រូបភាពទី៥-ការផ្សាំតាមរបៀបលោក Forkert

### ៣.៧.១.២-ការបំបៅតាមអក្សរ H :

-ចៀវសំបកដើមទំរជាអក្សរ H

-ចៀវពន្លកបំបៅដូចរបៀប Forkert ដែរ ដោយប្រវែងបណ្ដោយ និង ទទឹងរប

ពន្លកបំបៅ ស្មើនឹងប្រវែងចៀវរបស់ ដើមទំរ

-យកពន្លកបំបៅទៅបិតភ្ជាប់នឹងដើមទំរ ដោយទាញសំបកដែលគេចៀវរាងអក្សរ H

រួចទុកប្រឡោះសំរាប់ផ្អែកលូតលាស់

-បន្ទាប់មករុំបង់ប្លាស្ទិច

-ទុករយៈពេល ១៥ ថ្ងៃ រួចស្រាយពិនិត្យមើលភ្នែកពន្លក



រូបភាពទី៦-ការផ្សាំតាមរបៀបអក្សរ (H)

១-ចៀវសំបកឈើទំរ ២-ចៀវភ្នែកបំពៅ ៣-បញ្ចូលភ្នែកបំពៅទៅដើមទំរ

៤-គ្របសំបកដើមទំរ ៥- រុំបង់ប្លាស្ទិចអោយជិតល្អ ៦-ភ្នែកបំពៅចាប់ផ្តើមដុះឡើង

### ៣.៧.១.៣-ការបំពៅតាម Placage :

-ដើមទំរមានអាយុ ១-២ ឆ្នាំ

-កំពស់ពីផ្ទៃដី ៣០-៤០ ស.ម

-បង្អួចរាងការេ : ១,២-១,៥ ស.ម

-ទំហំភ្នែកបំពៅ ប៉ុន ឬ តូចជាងទំហំបង្អួចរបស់ដើមទំរ រួចផ្អិបភ្ជាប់ទៅនឹងបង្អួច

-រួចរុំនឹងបង់ប្លាស្ទិចអោយជិត

-ទុករយៈពេល ១៥ ថ្ងៃ រួចស្រាយពិនិត្យមើលភ្នែកពន្លក

-បើនៅពណ៌បៃតងមានន័យថារស់

-ពន្លកដុះបាន ១០ ស.ម កាត់ផ្នែកខាងលើនៃដើមទំរចោល ចំងាយពីភ្នែកបំពៅ ២-៥ ស.ម

-ពន្លកដុះនៅខ្ចីត្រូវយកបង្គោលមកចងផ្ទោប



រូបភាពទី៧-ការផ្សាំរាងជាការេ

១-ចៀវសំបកដើមទំរជាការេចោល ២-ចៀវភ្នែកបំពៅ ៣-បញ្ចូលភ្នែកបំពៅ

៤- រុំបង់ប្លាស្ទិចអោយជិតល្អ ៥- ភ្នែកបំពៅដុះនិង ការកាត់ចុងនៃដើមទំរចោល

### ៣.៧.១.៤-ការបំពៅតាម T :

-ដើមទំរមានអាយុ ១-២ ឆ្នាំ

-កំពស់ពីផ្ទៃដី ៧-១០ ស.ម

-ចៀវសំបករាងអក្សរ T

-ពន្លក បណ្តោយ ២,៥-៣ ស.ម ទទឹង ០,៥ ស.ម

-យកពន្លកមកស៊កក្នុងសំបកនៃដើមទំរ

-រួចរុំនឹងបង់ប្លាស្ទិចអោយជិត

-ទុករយៈពេល ១៥ ថ្ងៃ រួចស្រាយពិនិត្យមើលភ្នែកពន្លក

-បើនៅពណ៌បៃតងមានន័យថារស់ ត្រូវរុំសារជាថ្មីដោយទុកចន្លោះកន្លែងភ្នែកពន្លក

-ពន្លកដុះបាន ១០ ស.ម កាត់ផ្នែកខាងលើនៃដើមទំរចោល ចំងាយពីភ្នែកបំបៅ ២-
៥ ស.ម

-ពន្លកដុះនៅខ្ចីត្រូវយកបង្គោលមកចងផ្ទោប



រូបភាពទី៨-ការផ្សាំតាមរបៀបអក្សរ (T)

១-ចោះសំបកដើម ទំរជាអក្សរទផ្កាប់ ២-ជៀវភ្នែកបំបៅ ៣-បញ្ចូលភ្នែកបំបៅ
៤-ដាក់ភ្នែកបំបៅអោយបានស៊ប់ ៥- រុំបង់ប្លាស្ទិចអោយជិតល្អ ៦- ភ្នែកបំបៅដុះលូតលាស់

**៣.៧.២-ការបំបៅដោយអខ្ចត់ :**

**៣.៧.២.១-ការបំបៅតាម Coulee :**

-ដើមទំរមានអាយុ ១-២ ឆ្នាំ

-កំពស់ពីផ្ទៃដី ៧-១០ ស.ម

-ចៀរសំបករាងអក្សរ T

-ខ្នែងបំបៅរាងមុខពន្លាក ប្រវែង ៤-៥,៥ ស.ម

-យកខ្នែងបំបៅមកស៊កក្នុងសំបកនៃដើមទំរ

-រួចរុំនឹងបង់ប្លាស្ទិចអោយជិត

-ទុករយៈពេល ១៥ ថ្ងៃ រួចស្រាយពិនិត្យមើលភ្នែកពន្លក

-បើនៅពណ៌បៃតងមានន័យថារស់ ត្រូវរុំសារជាថ្មីដោយទុកចន្លោះកន្លែងភ្នែកពន្លក

-ពន្លកដុះបាន ១០ ស.ម កាត់ផ្នែកខាងលើនៃដើមទំរចោល ចំងាយពីភ្នែកបំបៅ២-
៥ ស.ម

-ពន្លកដុះនៅខ្ចីត្រូវយកបង្គោលមកចងផ្ទោប



១-ខ្នែងបំបៅដែលបានរៀបចំមើលពីចំហៀង

២-ខ្នែងផ្សាំដែលបានរៀបចំមើលពីមុខ

៣-ចោះសំបកដើមទំរ

៤-បញ្ចូលខ្នែងបំបៅ

រូបភាពទី៩-ការផ្សាំតាមរបៀប Coulée

### ៣.៧.២.២-ការបំបៅតាម **Fente de cote :**

-ដើមទំរមានអាយុ ៦ ខែ-១ ឆ្នាំ

-កំពស់ពីផ្ទៃដី ២០-៣០ ស.ម

-អង្កត់ផ្ចិតដើមទំរ ៦-២០ ម.ម

- ចិតបញ្ឆិតជារាងអណ្តាត ក្នុងជំរៅ ១/៣ នៃអង្កត់ផ្ចិត

-ខ្នែងបំបៅប្រវែង ៦-១០ ស.ម អង្កត់ផ្ចិតស្មើ ឬ តូចជាងដើមទំរ

-ខ្នែងបំបៅត្រូវចិតជារាងមុខពន្លាក

-យកខ្នែងបំបៅស៊កចូលទៅក្នុងដើមទំរ

-រួចរុំនឹងបង់ប្លាស្ទិចអោយតឹង រួចកាត់ផ្នែកខាងលើនៃដើមទំរ ដោយទុកតែប្រវែង ១៥-២០ ស.ម ពីកន្លែងបំបៅ

-ទុករយៈពេល ១៥ ថ្ងៃ រួចស្រាយពិនិត្យមើលភ្នែកពន្លក



១-ឈើផ្សាំដែលបានរៀបចំមើលពីមុខ

២-ឈើផ្សាំដែលបានរៀបចំមើលពីចំហៀង

៣-ឈើទំររៀបចំហើយ

៤-ការបិទឈើផ្សាំជាមួយឈើទំរ

រូបភាពទី១០-ការផ្សាំតាមរបៀបចិតខ្នែងជារាងមុខព្រលាក

### ៣.៧.២.៣-ការបំបៅដោយចចមែកផ្សោប :

-ចៀរគល់នៃដើមទំរ និង មែកនៃមែកផ្សាំ

-ចងផ្ដោបគ្នាកន្លែងចៀរ

-រយៈពេល១-៣ ខែ

-ត្រូវកាត់មែកឬដើមនៃដើងទំរ និង កាត់គល់នៃមែកផ្សាំ

-កាត់យកមកផ្សាំនឹងកន្ទោងសិនមុនយកទៅដាំ

### ៣.៧.២.៤-ការផ្សាំដោយភ្ញូលមែក :

**ក-ជ្រើសរើសជើងទំរ :**

-ជ្រើសរើសរកពូជណាដែរមានប្រព័ន្ធឫសរឹងមាំ

-ធន់នឹងជំងឺ និង សត្វល្អិតក្នុងដី

-ប្រភេទដើមធំ លូតលាស់ល្អ

**ខ-មែកពូជ :**

-រើសយកពីដើមណាដែលមានដើមដងល្អ ផ្ដល់ផលខ្ពស់

-ធន់នឹងជំងឺ និង សត្វល្អិត

-យកមែកដែលនៅខ្ចីល្មម

## ៤ ការសាកដោយចៀរសំបក :

-ជ្រើសរើសយកមែកណាដែលមានអាយុចំណាស់

-មានទំហំប្រមាណប៉ុនមេដៃ

-ជាមែកដែលផ្ដល់ផលច្រើន និង គ្មានជំងឺ

-វាស់ប្រវែងពីចុងមែកប្រមាណ ១ ម៉ែត្រ

-ចៀរសំបកចោលទំហំប្រមាណ ១.៥ ស.ម

-ត្រូវយកដីលាយនឹងជីធម្មជាតិមកបិទកន្លែងចៀរ

-យកស្រកីដូង ឬ ថង់ប្លាស្ទិចមករុំឱ្យបានជិតល្អ

-អនុវត្តនៅរដូវភ្លៀង បើពុំមានភ្លៀងត្រូវសំរក់ទឹកលើស្រកីដូង

-ប្រមាណ ២-៣ ខែទើបដុះឫស

# មូលហេតុនៃការជ្រុះរបស់ផ្កា និង ផ្លែ

## ១.ការផ្លាស់ប្តូរអាកាសធាតុ :

-ការចេញផ្កាក្នុងអំឡុងពេលដែលមានអាកាសធាតុផ្លាស់ប្តូរ ដូចជារងា ឬ អាកាសធាតុក្តៅច្រើនជាងធម្មតា ជាហេតុធ្វើអោយមានការជ្រុះផ្កាច្រើន រីឯផ្លែដែលជាប់ភាគច្រើនមានខ្នាតតូច ។ បើមានផ្លាស់ប្តូរអាកាសធាតុនៅពេលមានផ្លែ គេសង្កេតឃើញថា ផ្លែមានការធ្លាក់ច្រើនបំផុត ផ្លែដែលជ្រុះគេឃើញមានស្នាមរយៈត្រង់ស្នាមភ្ជាប់របស់ផ្លែ និង ទងផ្លែ

-ដើម្បីការពារនៅពេលមានអាកាសធាតុផ្លាស់ប្តូរ គេប្រើអ័រម៉ូន N.A.A 1-2 cc/ 20 l $H_2O$

## ២.សត្វល្អិត និង ជំងឺ :

-នៅពេលចេញផ្កា និង ផ្លែនៅខ្ចី វាត្រូវបានចៃភ្លើង និង ចៃក្រហម ដែលបំផ្លាញដោយបឺតជញ្ជាក់យកសារធាតុចិញ្ចឹមពីផ្កា និង ផ្លែខ្ចី ធ្វើអោយស្វិតបន្ទាប់មកជ្រុះ ចំណែកផ្លែវាបំផ្លាញនៅលើសំបក ។ រីឯផ្លែធំខ្លះក៏អាចជ្រុះរលួយខូចដោយសារការបំផ្លាញពីសត្វមេអំបៅ និង រុយមាស ។ចំណែកឯផ្លែជ្រុះខ្លះទៀត មកពីជំងឺ ខែងហ្គ័រ ដែលបណ្តាលមកពីការឆ្លងតាមរយៈការបំផ្លាញពីចៃភ្លើង និង ចៃក្រហម ធ្វើអោយជំងឺផ្សិតនេះចូលទៅបំផ្លាញត្រង់កន្លែងរបួសនោះ

-ចំណែកឯផ្លែចាស់ខ្លះទៀតដែលកើតជំងឺក្រិន ឬ ជំងឺវីរុសទ្រីសតេសា ក៏អាចធ្វើអោយផ្លែធ្លាក់ដែរ

## ៣.ជី

-ជីមានសារៈសំខាន់ក្នុងការលូតលាស់របស់ផ្កានិង ការបង្កើតផ្កា ។ នៅពេលដែលទទួលជីមិនគ្រាប់គ្រាន់ ឬ ច្រើនលើសពីតំរូវការក៏ ជាហេតុនាំអោយមានការជ្រុះផ្កា ព្រោះថាការផ្តល់ធាតុអាសូតច្រើនពេក ឬ បណ្តាលមកពីធាតុចិញ្ចឹមត្រូវបានយកទៅចិញ្ចឹមផ្នែកត្រួយខ្ចី និង ស្លឹក ។ គេអាចការពារបានដោយប្រើជីដែលមានហ្វូស្វ័រ និង ប៉ូតាស្យូមខ្ពស់ ដើម្បីជួយកែប្រែជីអោយបានសមស្រប ។

## ៤.ទឹក

-ទឹកមានសារៈសំខាន់ជួយក្នុងការបង្កើតផ្កា ក្នុងពេលមុនចេញផ្កា រុក្ខជាតិត្រូវការសំរាកការលូតលាស់ផ្នែកសរីរាង្គលូតលាស់ ត្រូវការទឹកតិចតួចបំផុត ដើម្បីរបមូលអាហារទុកក្នុងការបង្កើតផ្កា ។ ការបើរុក្ខជាតិទទួលទឹកច្រើនជាងធម្មតា នៅដំណាក់កាលចេញផ្កាធ្វើអោយផ្កានោះមានការជ្រុះច្រើន ។

-ក្នុងដំណាក់កាលកំពុងកាន់ផ្កា និងមានផ្កាកំពុងរីក បើប្រើទឹកលើសនាំអោយផ្កាជ្រុះច្រើន តែបើការផ្តល់ទឹកខ្វះក្នុងដំណាក់កាលនោះ ក៏ធ្វើអោយក្រូចមានផ្លែជ្រុះ ផ្លែតិចហើយតូច

## ៥.អាយុ និង លក្ខណៈល្អរបស់ដើម

-ឈើហូបផ្លែដែលមានអាយុតិច មានសមត្ថភាពក្នុងការបង្កើតផ្កា និង ជាប់ផ្លែនតិច តែលូតលាស់ផ្នែកដើម ស្លឹក ឫសបានល្អ

-នៅពេលឈើហូបផ្លែមានអាយុច្រើន នោះវាមានសមត្ថភាពក្នុងការបង្កើតផ្កា និងផ្លែ បានច្រើនរហូតដល់ចំណុចខ្ពស់បំផុត ។ នៅពេលឈើហូបផ្លែមានអាយុចាស់ នោះសមត្ថភាពរបស់វា ក្នុងការបង្កើតផ្កា និង ផ្លែបានថយចុះជាលំដាប់

# រូបធាតុជីគីមី

ជីគឺជាសារធាតុផ្សេងៗ ដែលយើងបន្ថែម ឬ បាចទៅលើដីដែលអាចផ្តល់នូវសារធាតុចិញ្ចឹមចាំបាច់សំរាប់រុក្ខជាតិលូតលាស់ ។

## ១.ជីសរីរាង្គ:

ជីសរីរាង្គ ឬជីធម្មជាតិវាមាន អត្ថប្រយោជន៍ ណាស់ ពីព្រោះវាមិនមែនតែសំរាប់ធ្វើអោយដីមានជីជាតិតែប៉ុណ្ណោះទេ វាថែមទាំងធ្វើអោយទំរង់ដីល្អ និង មានខ្យល់ចេញចូលក្នុងដីទៀតផង ធ្វើអោយដីធូរ ។

-ជាសារធាតុដែលបានមកពីរុក្ខជាតិ និង សត្វ ឬ កាកសំណល់ដូចជា : កំប៉ុស្តិ៍ ចំបើង ជីស្រស់

-បរិមាណច្រើន មានបរិមាណជីតិច

-ជីទាំងនោះមិនបំលែងភ្លាមៗ

-ធ្វើអោយលក្ខណៈរូបសាស្ត្ររបស់ដីល្អប្រសើរ

## ២.ជីអសរីរាង្គ:

-ជាសារធាតុដែលបានមកពីរ៉ែផ្សេងៗពី បរិយាកាស ឧស្ម័ន ទឹក .....

-មានកំរិតភាគរយនៃសារធាតុចិញ្ចឹមខ្ពស់ អាចរក្សាទុកសារធាតុចិញ្ចឹមបានយូរ

-ងាយស្រួលរុក្ខជាតិស្រូបយកបានរហ័ស និង ងាយរលាយក្នុងទឹក

-ជីគីមីមានតំលៃថ្លៃ ប្រើច្រើនធ្វើអោយខូចទំរង់ដី

-ការចាត់ថ្នាក់ជីគីមីដោយយោលទៅតាមចំនួនធាតុនៃជី :

+ជីទោល Single Fertilizer :

មានធាតុគីមីសំខាន់តែមួយគត់ N ឬ P ឬ K នៅក្នុងជីគីមីនោះ

ឧ-អ៊ុយរ៉េ N = 45-46 % ប៉ូតាស្យូមក្លរួ K = 60 %

+ជីទ្វេ Incomplete Fertilizer :

មានធាតុគីមីសំខាន់ពីរ N និង P នៅក្នុងជីគីមីនោះ :

ឧ- អាម៉ូនីញ៉ូមហ្វូស្វាត N=16,P=20 , ឌីអាម៉ូនីញ៉ូមហ្វូស្វាត N=18 ,P=46

+ជីគីមីគ្រប់មុខ Complete Fertilizer :

មានគ្រប់ធាតុគីមីសំខាន់ N , P , K នៅក្នុងជីតែមួយ

ឧ- ១៤-១៤-១៤ , ១៥-១៥-១៥ , ១២-២៤-១២

+ជីលាយ Mix Fertilizer : មានធាតុគីមីសំខាន់ពីរ ឬ ច្រើនមុខ

## ៣ វិធីដាក់ជី មានពីរបែប :

១-ការបាចជីទ្រាប់បាត :

ការបាចជីទ្រាប់បាតគឺធ្វើឡើងមុនពេលភ្ជួររាស់ ឬ លាយដាក់បាតរណ្តៅ

២-ការបាចជីបំប៉ន :

ការបាចបន្ថែមដើម្បីបង្កើនការដុះលូតលាស់

## ៤ ការគណនាបរិមាណជី

ការគណនាបរិមាណជីមានគោលបំណង :

-កំណត់ចំនួនត្រូវការ

-កំណត់នូវប្រភេទជីដែលមានតំលៃថោក និង ការលាយចូលគ្នានៃរូបធាតុជី

ការគណនារូបមន្តជី គឺបំលែងពីបទដ្ឋានប្រើប្រាស់ Recommended Rate (RR)ទៅជាចំនួនត្រឹមត្រូវរបស់រូបធាតុជី Fertilizer Materials (FM)

បទដ្ឋានប្រើប្រាស់វាសំដែងចេញចេញជា N P K គិតជាគីឡូក្រាមធាតុសកម្ម ក្នុងមួយហិកតា

បរិមាណរបស់រូបធាតុជីក្នុងមួយហិកតា :

ឧ-បទដ្ឋានប្រើប្រាស់ជីដែលគេអោយ : $RR = 90+60+30 = N_{90} P_{60} K_{30}$

-បរិមាណរបស់រូបធាតុជី ១៥-១៥-១៥ = ១២០ គីឡូក្រាមក្នុងមួយហិកតា

$$FM = \frac{RR \times A \times 100}{a.i\ \%}$$

RR បទដ្ឋានប្រើប្រាស់ គិតជា គ.ក្រ នៃធាតុសកម្ម/ហិកតា

FM បរិមាណរបស់រូបធាតុជី គិតជា គ.ក្រ/ហិកតា

A ផ្ទៃដី គិតជា ហិកតា

a.i % ធាតុសកម្មក្នុងជី គិតជាភាគរយ

# ថ្នាំពុលកសិកម្ម PESTICIDE

**១-វិធានការមេកានិច** (Mechanical Control)

ក-ការប្រើប្រាស់មុង ឬ សំណាញ់ (Netting or Bagging)

ខ-ពន្លិចទឹក ឬ បង្ហូរទឹកចេញពីស្រែ (Flooding and Drying the field)

គ-ការរុំការពារផ្លែ (Covering Fruit)

ឃ-ការប្រើរនាំង (Screlning)

ង-ការកំចាត់ដោយដៃ (Hand Picking)

ច-ការជីកចង្ហូរ (Making Small Canal)

ឆ-ការប្រើអង្គប់ (Using of Trap)

ជ-ទិវាកំចាត់កណ្តុរ (Rat Killing Day)

ឈ-ការប្រើអន្ទាក់ភ្លើង (Light Trap)

**២-វិធានការជីវសាស្ត្រ** (Biological Control)

ក-ប្រេដាទ័រ :

ខ-ប៉ារ៉ាស៊ីត :

គ-ភ្នាក់ងារបង្កជំងឺ :

**៣-វិធានការក្សេត្រសាស្ត្រ ឬ អនុវត្តការដាំដុះ** (Cultural Control or Plant Practice )

ក-ការផ្លាស់មុខដំណាំ (Crop Rotation)

ខ-ការដាំដំណាំចំរុះ (Mixed Crop)

គ-ការសំអាតការដាំដុះ (Clean Cultivation)

ឃ-ការអនុវត្តន៍ការដាំដុះអោយបានត្រឹមត្រូវ

ង-ការប្រើប្រាស់ពូជធន់

**៤-វិធានការគីមី** (Chemical Control Measures)

**៥-វិធានការចំរុះការពារដំណាំ** (Integrated Pest Managemaent-IPM

## ៦_ថ្នាំកំចាត់សត្វចង្រៃផ្សំពីរុក្ខជាតិ BOTANICAL PESTICIDE

### ៦.១-ទៀបស្រុក :

យកគ្រាប់ទៀបកិនអោយខ្ទេច លាយជាមួយនឹងទឹកសំរាប់បាញ់កំចាត់សត្វចៃស្រមោច កណ្តូប មមាចត្នោត មមាចខៀវ អណ្តើកមាសនិង ដង្កូវផ្សេងៗ ។

### ៦.២-ឈូករត្ន័ Sunflower :

យកផ្កាស្ងួតកិនអោយម៉ត់ លាយជាមួយដីឥដ្ឋម៉ត់ និង ទឹក អាចកំចាត់សត្វល្អិតបានច្រើនប្រភេទ ។ មេ្សាផ្កាស្ងួតចំនួន ៦-៧ ស្លាបព្រាបាយ សំរាប់លាយទឹក៤ លីត្រ ។

### ៦.៣-ក្បៀស Stemona tuberosa :

-យកសំបក និង មើមស្រស់ ទៅបុករួចច្រោះយកទឹកសំរាប់កំចាត់សត្វល្អិតបានយ៉ាងប្រសិទ្ធភាពបំផុត ។ ទឹកក្បៀស ៦ ស្លាបព្រាបាយ លាយនឹងទឹកធម្មតា ៣-៤ លីត្រ ។

-ឫសស្រស់ លាយជាមួយទឹកកំបោរអាចសំលាប់សត្វចៃបាន ។

### ៦.៤-ថ្នាំជក់ Tobacco :

ថ្នាំជក់ខ្លាំង ១ គ.ក្រ ត្រាំក្នុងទឹកក្តៅ ២ លីត្រ ទុក ១២ ម៉ោង បន្ទាប់មកលាយទឹក ២០ លីត្រ និង សាប៊ូ ២០ ក្រ សំរាប់កំចាត់សត្វចៃ ។

### ៦.៥-ផេះចង្ក្រាន Ash :

-យកផេះត្រជាក់រោយជុំវិញគល់ ហើយយកដីលប់បន្តិចៗពីលើ សំរាប់កំចាត់ដង្កូវបំផ្លាញឫសស្ពៃ ឆៃថាវ ខ្ទឹមបារាំង ។ល។

-ធ្វើរណ្តៅទទឹង ៣-៥ ធ្នាប់ជុំវិញគល់ និង ជំរៅ ២-៣ ថ្នាំងដៃ ដាក់ផេះអោយពេញ អាចការពារបាននូវពួកកូនខ្ចង និង ដង្កូវប្រផេះ ។

-កំចាត់កូនខ្ចងចោះស្លឹក ត្រូវយកផេះលាយទឹកបាញ់

-កំចាត់សត្វអណ្តើកមាសបំផ្លាញត្រសក់ ត្រូវយកផេះពាក់កណ្តាល លាយនឹងទឹកសាប៊ូបាញ់ ។

### ៦.៦-បុកថ្នាំសន្លឹកម្ទេស ខ្ទឹមស ខ្ទឹមបារាំង សន្លឹកជីនាងវង

ច្រោះយកទឹក រួចលាយទឹកធម្មតាស្មើផាគគ្នា បាញ់សំរាប់ការពារសត្វល្អិតច្រើនប្រភេទ ។

### ៦.៧-ប្រេងកាត លាយទឹកសាប៊ូ

យកម្សៅសាប៊ូកន្លះពែង លាយប្រេងកាតកន្លះស្លាបព្រាបាយ និង ទឹក ១លីត្រ សំរាប់បាញ់កំចាត់សត្វល្អិតច្រើនប្រភេទ ។

### ៦.៨-ក្រដាសកញ្ចប់បារី ឬ កំប៉ុង

ដង្កូវហ្វូងជាពួកដង្កូវ ដែលកាត់សំណាបពេលយប់ ដូច្នេះត្រូវយកក្រដាសកញ្ចប់បារី ឬកំប៉ុងហ៊ុំព័ទ្ធពីក្រៅ អោយបានកំពស់ ៣ ធ្នាប់ និង ចុះទៅក្នុងដី ១ធ្នាប់ ។

### ៦.៩-ដាក់អន្ទាក់រុយស

យកបន្ទះដែកដែលមានពណ៌លឿងភ្លឺរលោង ឬ ពណ៌ទឹកក្រូចមកលាបប្រេងស្អិត ឬទឹកឃ្មុំ ដើម្បីទាក់ទាញរុយសអោយមកទុំស្អិតជាប់ និង ងាប់នៅលើបន្ទះដែកនោះ ។ ត្រូវថែមប្រេងស្អិត ឬ ទឹកឃ្មុំ ៣-៤ ថ្ងៃម្តង ។

### ៦.១០-ខ្ទឹមស ខ្ទឹមបារាំង និង ម្រះ

រាល់ផ្ទៃដី ៣០ ម² ត្រូវដាំម្រះនៅតាមបណ្តោយសងខាងនៃរង អោយបានចំនួន ៨-១០ដើម និង ខ្ទឹមស ឬខ្ទឹមបារាំងត្រូវដាំឆ្លូកក្នុងរងអោយបាន ២០-២៥ គុម្ព ។

### ៦.១១-ទឹកសាប៊ូ

ចិតចំណិតសាប៊ូស្តើងៗចំនួន ៣ ស្លាបព្រាបាយ លាយទឹក ៣.៥ លីត្រ អាចយកទៅបាញ់កំចាត់សត្វល្អិតច្រើនប្រភេទ ។

### ៦.១២-ខ្ទឹមស ខ្ទឹមបារាំង ម្ទេស ស្លឹកម្រះ

យកខ្ទឹមស ៣-៤ កំពិស ស្លឹកម្រះ ២ ដៃ ខ្ទឹមបារាំង ២-៣ ដុំ ម្ទេស ២-៣ផ្លែ បុកអោយម៉ត់ ហើយយកទៅដាំអោយពុះ រួចទុកអោយត្រជាក់ លាយទឹកថែម ៤-៥ ភាគរយ កូរអោយសព្វ ហើយយកទៅបាញ់កំចាត់សត្វល្អិតច្រើនប្រភេទប៉ុន្តែមិនត្រូវទុកអោយលើស ២ ថ្ងៃឡើយ ។

## ៧-ថ្នាំពុលគីមី (ថ្នាំពុលកសិកម្ម) Chemical pesticides

### ៧.១-លក្ខណៈទូទៅ :

ថ្នាំពុលគីមីជាប្រភេទថ្នាំផលិតចេញពីរោងចក្រដែលអាចសំលាប់ ឬ កំចាត់កត្តាចង្រៃមានដូចជា :

| | |
|---|---|
| -សត្វល្អិត | Insect |
| -ផ្សិត | Fungi |
| -ស្មៅចង្រៃ | Weeds |
| -បាក់តេរី | Bacteria |
| -ណេម៉ាតូត | Nematodes |
| -ចៃ | Mites |
| -ខ្យង | Snail |
| -វីរុស | Virus |

ដែលបណ្តាលអោយខូចខាតដល់ដំណាំ និង ស្បៀងរក្សាទុក ។

ថ្នាំពុលអាចចាត់តាំងជាក្រុម ដោយយោលទៅតាមប្រសិទ្ធិភាពក្នុងការកំចាត់កត្តាចង្រៃនិមួយៗដូចតទៅ :

| | | |
|---|---|---|
| -ថ្នាំសំលាប់សត្វល្អិត | (Insecticide) | សំរាប់កំចាត់សត្វល្អិត |
| -ថ្នាំសំលាប់ផ្សិត | (Fungicide) | សំរាប់កំចាត់ផ្សិត |
| -ថ្នាំសំលាប់ស្មៅចង្រៃ | (Herbicide) | សំរាប់កំចាត់ស្មៅចង្រៃ |
| -ថ្នាំសំលាប់បាក់តេរី | (Bactericide) | សំរាប់កំចាត់បាក់តេរី |
| -ថ្នាំសំលាប់ណេម៉ាតូត | (Nematicide) | សំរាប់កំចាត់ណេម៉ាតូត |
| -ថ្នាំសំលាប់ចៃ | (Miticide or Acaricide) | សំរាប់កំចាត់ចៃ |
| -ថ្នាំសំលាប់ខ្យង | (Molluscicide) | សំរាប់កំចាត់ខ្យង |

### ៧.២-ការជ្រើសរើសថ្នាំពុលកសិកម្ម (Choice of Pesticide)

-ត្រូវស្គាល់ប្រភេទនៃកត្តាចង្រៃ និង សំរេចថា តើពេលណាដែលចាំបាច់ត្រូវប្រើថ្នាំ

-បើមិនច្បាស់ ត្រូវស្វែងរកយោបល់ណែនាំរបស់ភ្នាក់ងារកសិកម្ម ឬ របស់ក្រុមហ៊ុនលក់ថ្នាំកសិកម្ម

-អ្នកប្រើប្រាស់ថ្នាំត្រូវតែដឹងពី :

◇ ថ្នាំដែលត្រូវយកមកប្រើប្រាស់ និង គ្រោះថ្នាក់របស់ថ្នាំ

◇ កំរិតលាយថ្នាំ

◇ វិធីនៃការប្រើប្រាស់

◇ពេលវេលា និង ចំនួនដងនៃការប្រើប្រាស់

◇វិធីបង្ការគ្រោះថ្នាក់

## ៧.៣_ការធ្វើអោយកខ្វក់ដល់បរិយាកាសធម្មជាតិ Pollution of the Environment

មូលហេតុរួមនៃការធ្វើអោយកខ្វក់ :

-ការហៀរកំពប់ លេច ធ្លាយ នៅពេលដឹកជញ្ជូន ស្តុកទុក លាយ និងនៅពេលប្រើប្រាស់

-ការរៀបចំទុកដាក់ធុងថ្នាំ ថ្នាំសេសសល់ ឬ ទុកកញ្ចប់ថ្នាំក្នុងស្រែចំការ

-ចាក់ទឹកថ្នាំដែលលាយរួច ឬ ទឹកលាងបំពង់បាញ់ថ្នាំទៅក្នុងទន្លេ បឹងបួរ ឬទៅលើមាត់ផ្លូវ

-លាយថ្នាំលើសកំរិត ហើយបាញ់ក្នុងពេលខ្យល់បក់ខ្លាំង ដែលនាំអោយទឹកថ្នាំខ្ចាតចេញឆ្ងាយ

-មិនត្រូវប្រើប្រាស់ថ្នាំសំលាប់សត្វល្អិតនៅជិតមាត់ស្ទឹង បឹងបួរ ដែលជាប្រភពទឹកសំរាប់ប្រើប្រាស់ ឬសំរាប់ចិញ្ចឹមត្រី

-ត្រូវធានាសុវត្ថិភាពដល់សត្វមានប្រយោជន៍ដូចជា សត្វស្លាប ពស់ និងសត្វល្អិតមានប្រយោជន៍ ដែលរួមចំណែកក្នុងការកំចាត់កណ្តុរ និង សត្វល្អិតចង្រៃ

## ៧.៤_ការពុលដល់មនុស្ស និង សត្វ

ថ្នាំសំលាប់សត្វចង្រៃចូលក្នុងខ្លួនតាមតាមរយៈ :

-ស្បែក :

◇ពេលដែល ដៃ ភ្នែក មុខ ដែលគ្មានរបាំងការពារ ប៉ះត្រូវទឹកថ្នាំសុទ្ធ ឬ ទឹកថ្នាំលាយ

◇ពេលដែលសំលៀកបំពាក់សើម ឬ ប្រឡាក់ដោយថ្នាំពុល

◇នៅពេលដែលយើងពាក់ស្បែកជើងឬ ស្រោមដៃរហែក

◇ពេលដែលអ្នកបាញ់ ត្រូវទឹកថ្នាំជះមកលើ

-មាត់

◇មិនត្រូវហូប ផឹក ឬ ជក់បារីពេលប៉ះពាល់នឹងថ្នាំពុល

◇មិនត្រូវប្រើមាត់ផ្លុំក្បាលបិចដែលស្ទះ

-ការដកដង្ហើម

◇ជៀសវាងដកដង្ហើមចូលនូវធូលី ឬ ចំហាយទឹកថ្នាំ

◇ត្រូវបាញ់ថ្នាំបណ្តោយខ្យល់

◇ត្រូវប្រើប្រាស់ប្រដាប់ដកដង្ហើមក្នុងករណីមានការណែនាំ

## ៧.៥_ការដាក់ផ្លាក (The Label)

ជាមូលដ្ឋានដល់ការប្រើប្រាស់ថ្នាំ ប្រកបដោយប្រសិទ្ធិភាព និង សុវត្ថិភាព ចាំបាច់ត្រូវតែអាន ហើយសរសេរជាភាសាជាតិលើកញ្ចប់និមួយៗ ។ បើផ្លាកមិនអាចសរសេរអោយបានគ្រប់នូវពត៌មានទេ ត្រូវសរសេរបន្ថែមលើឯកសារបោះពុម្ពដោយឡែក ។ ត្រូវតែអានការណែនាំនៅលើផ្លាក មុននឹងប្រើប្រាស់ថ្នាំ ព្រោះគ្មានផលិតផលគីមីណា ដែលគ្មានគ្រោះថ្នាក់ទាំងស្រុងនោះទេ ។

ចំណុចសំខាន់ដែលមាននៅលើផ្លាក :

-ថ្នាំដែលប្រើនោះ ជាថ្នាំសំរាប់កំចាត់អ្វី

-ថ្នាំនេះមានកំរិតពុលណាខ្លះដល់អ្នកប្រើប្រាស់

-តើមានសញ្ញាអ្វីដែលប្រាប់អោយអ្នកប្រើប្រាស់ដឹងអំពីគ្រោះថ្នាក់ឬទេ ?

-តើវិធីបង្ការគ្រោះថ្នាក់យ៉ាងណាខ្លះ ?

-តើមានប្រតិកម្មកាកសំណល់ធ្ងន់ធ្ងរយ៉ាងណា ?

## ៧.៦_ការវេចខ្ចប់ (Packing) :

-រាល់កញ្ចប់ថ្នាំត្រូវតែបិទផ្លាកអោយបានត្រឹមត្រូវ គឺបិទភ្ជិត និង ដាក់សញ្ញាសំគាល់ដើម្បីបង្ការការលេច ធ្លាយ ឬ បាត់ផ្លាក ។

-បើសិនកញ្ចប់នេះត្រូវបានគេក្លែងបន្លំ ឬ ផ្លាស់ប្តូរពីភាពដើម យើងអាចដឹងភ្លាម ។ មិនត្រូវហែកកញ្ចប់ដើម ហើយរំលែកទៅជាកញ្ចប់តូចៗ ឬ ក៏យក ទៅច្រកក្នុងដប កំប៉ុង ដើម្បីដាក់លក់នោះទេ ។

## ៧.៧_ការខូចខាត (Damage) :

ត្រូវលើកដាក់ធុងដែលមានថ្នាំអោយថ្នមដៃ ឬ ខ្វះការប្រុងប្រយ័ត្នត្រួតពិនិត្យ ធុងដាក់ថ្នាំជាទៀងទាត់រែកងមានការលេច ធ្លាយ ឬ មានសញ្ញាខូចខាតណាមួយដូចជា ស្នាមប្រឡាក់ ស្នាំច្រេះ និង គំរបធុងរលុង ។

ការប្រើប្រាស់ធុងចាស់ វានឹងលេចធ្លាយថ្នាំ នៅពេលដែលយើងប្រមៀល ឬលើកដាក់ ។ ក្នុងករណីមានធុងលេចត្រូវយកវាចេញជាបន្ទាន់ តែបើថ្នាំនៅល្អត្រូវផ្ទេរវាទៅធុងថ្មី រួចបិទផ្លាកថ្មីអោយដូចផ្លាកធុងដែលលេចនោះ ។

## ៧.៨_ការស្តុក និង ការដាក់តាំង (Storage and Display)

-ថ្នាំពុលកសិកម្មមានតំលៃថ្លៃ ហើយអាចខូចគុណភាពប្រើប្រាស់លែងកើតព្រមទាំងបង្កគ្រោះថ្នាក់ បើសិនជាយើងស្តុកយូរពេក ឬ កន្លែងដែលស្តុកមានលក្ខណៈមិនសមស្រប ។

-ត្រូវមានផែនការច្បាស់លាស់ក្នុងការទិញថ្នាំពុលកសិកម្ម ដើម្បីបន្ថយរយៈពេលស្តុកទុក និង ជៀសវាងការប្រើប្រាស់សល់

-ថ្នាំពុលអាចខូចគុណភាពយ៉ាងឆាប់រហ័ស ក្រោយពីយើងបើកធុងប្រើ

-ជៀសវាងដាក់ថ្នាំក្នុងឃ្លាំងដែលមានកំដៅខ្ពស់ ឬ ទុកចោលក្រោមកំដៅថ្ងៃ

-ថ្នាំពុលកសិកម្មត្រូវទុកអោយឆ្ងាយពីកុមារ ឬ ពីសត្វ

-មិនត្រូវស្តុកទុកថ្នាំសំលាប់សត្វល្អិតក្បែរចំណីអាហារ ឬ ទឹកប្រើប្រាស់

-បុគ្គលិកទាំងអស់ដែលធ្វើការក្នុងឃ្លាំងស្តុកថ្នាំ និង ក្នុងអាគារលក់ថ្នាំ ត្រូវតែទទួលការបំពាក់បំប៉ន ស្បៀក សំល្បៀកបំពាក់ការពារនៅពេលធ្វើការ ។

-ខ្យល់ចេញចូលមានសារៈសំខាន់បំផុត ដើម្បីបញ្ចោញនូវឧស្ម័នពុល ឬចំហាយឆេះ និង ធូលី

### ៧.៨.១-ស្តុកដោយមានរបៀបរៀបរយ (Storage orderly)

-គរធុង ឬ កេសថ្នាំក្នុងស្ថានភាពមិនងាយដួលរលំ ឬ មិនខ្ពស់ពេក ដើម្បីងាយស្រួលដល់ការឈោងយក ។

-រក្សាកន្លែងដែលទំនេរស្អាត និង មានរបៀបរៀបរយ ដោយទុកអោយមានចន្លោះដើរ រវាងគំនរថ្នាំ និង ទូរដាក់ថ្នាំ ។ រក្សាផ្លូវចេញចូល កុំឱ្យមានការរាំងស្ទះ

-មិនត្រូវដាក់ធុងថ្នាំ និង កេសថ្នាំផ្ទាល់ដីទេ ត្រូវកល់នឹងឥដ្ឋ ឬ ឈើកំណល់

-ត្រូវប្រើប្រព័ន្ធបញ្ចូលមុន បញ្ចេញមុន

### ៧.៨.២-ការដាក់តាំង (Display of Pesticide in Shops)

ការដាក់តាំងដោយមានរបៀបរៀបរយក្នុងទូរដាក់តាំង បង្កឱ្យមានសុវត្ថិភាពនិង លក់បានច្រើន ។ គ្រោះថ្នាក់បណ្តាលមកពីថ្នាំពុល ច្រើនកើតមានឡើងនៅក្នុងអាគារលក់ដូរ ដូច្នេះដើម្បីការពារគេត្រូវ :

-ថ្នាំដែលមានគ្រោះថ្នាក់ខ្លាំង ត្រូវរក្សាទុកក្នុងកញ្ចប់ ឬ បន្ទប់ដែលមានទ្វារ បិទជិត

-កញ្ចប់ថ្នាំ ឬ ដបថ្នាំ មិនត្រូវគរលើតុលក់ដូរ ឬលើកំរាល

-មិនត្រូវទុកធុងដាក់ថ្នាំដូចគ្នាច្រើនពេកក្នុងអាគារលក់ដូរទេ

-មិនត្រូវដាក់តាំងថ្នាំពុល ក្បែរចំណីអាហារ ឬ ថ្នាំពេទ្យ ឬ ឥវ៉ាន់ប្រើប្រាស់

-មិនត្រូវលក់ថ្នាំពុលដែលមានគ្រោះថ្នាក់ខ្លាំងដល់កុមារទេ

-ត្រូវត្រៀមសាប៊ូ ទឹក និង កន្សែងជូតដៃ សំរាប់អ្នកទិញ ពេលណាមានប្រឡាក់ដៃដោយថ្នាំពុល

-ត្រូវដាក់សញ្ញាគ្រោះថ្នាក់ថ្នាំពុល ក្នុងអាគារលក់ដូរ នៅកន្លែងណាដែលអាច មើលឃើញ

## ៧.៩-ការដឹកជញ្ជូន (Transport)

មិនត្រូវផ្ទុកថ្នាំពុលក្នុងរថយន្តដែលដឹកអ្នកដំណើរ ឬ ម្ហូបអាហារ។ បើមិនអាចជៀសបានត្រូវផ្ទុកថ្នាំដោយលែកឆ្ងាយពីអ្នកដំណើរ និង ឥវ៉ាន់អ្នកដំណើរ ។

វិធានការបង្ការគ្រោះថ្នាក់មួយចំនួននៅពេលដឹកជញ្ជូន :

-ដែកគោលដែលលយចេញពី បន្ទះដែក បំណែកឈើនៅលើរថយន្ត អាចទំលុះកញ្ចប់ ហើយបណ្តាលអោយធ្លាយ ថ្នាំចេញ ត្រូវរើវត្ថុទាំងនេះចេញមុនផ្ទុកថ្នាំពុលកសិកម្ម

-មិនត្រូវបណ្តោយអោយធុងថ្នាំធ្លាក់ចុះពីលើឡើយ

-ត្រូវចងរឹតបន្ទុកថ្នាំអោយបានមាំហើយមិនត្រូវផ្ទុកថ្នាំលើគែមដំបូលរថយន្តទេ

-ត្រូវពិនិត្យថ្នាំដែលដាក់ចុះពីរថយន្ត តើមានលេចធ្លាយ គំរបធូរលុង ផ្លាករហែកឬទេ ហើយបើមានត្រូវជួស ជុល ឬ ខ្ចប់ឡើងវិញភ្លាមមុននឹងយកទៅស្តុកទុក

ពេលមានគ្រោះថ្នាក់ចរាចរ ការហៀរថ្នាំចេញ ឬ ការលេចធ្លាយក្នុងពេលកំពុងដឹកជញ្ជូន ត្រូវអនុវត្តដូចតទៅ :

-ខិតខំទប់ការហៀរចេញ

-ដេញមនុស្ស និងសត្វចេញអោយឆ្ងាយ

-រោយដី ឬ អាចម៍រណាដើម្បីផ្តិតយកទឹកថ្នាំ ឬបោសសំអាតអោយជ្រះដោយប្រុងប្រយ័ត្នបំផុត

-ម្សៅ ឬ គ្រាប់ថ្នាំដែលខ្ចាតចេញត្រូវបោសសំអាត ដោយមិនបណ្តោយអោយហុយឡើង

-លាងសំអាតកន្លែងនៅលេរថយន្តដែលប្រឡាក់ថ្នាំអោយបានជ្រះស្អាត

-ជីកកប់កាកសំណល់ អោយបានជំរៅកន្លះម៉ែត្រ នៅកន្លែងដែលមិនបណ្តោយ

## ៧.១០_ថ្នាំដែលហៀរហូរចេញ ត្រូវតែលាងសំអាតជាបន្ទាន់

មិនត្រូវប្រើទឹកច្រើន ដើម្បីលាងសំអាតទឹកថ្នាំដែលហៀរហូរចេញនោះទេព្រោះអាចបណ្តាលអោយថ្នាំបាចសាច កាន់តែធំឡើង ។ ទឹកថ្នាំដែលហៀរហូរត្រូវតែយកដីខ្សាច់ ឬ អាចម៍រណារោយពីលើ ហើយបោសសំអាតប្រមូលកើបដាក់ ធុងឬ ស្បោងប្លាស្ទិច ដោយមានដាក់សញ្ញាត្រឹមត្រូវយកទៅបោះចោល ។ រោយដីខ្សាច់សើម ទៅលើម្សៅថ្នាំដែលកំពប់ មុននឹងបោសវាចេញ ដើម្បីជៀសវាងការហុយឡើង ។ បន្ទាប់មក លាងសំអាតដៃដែលប្រឡាក់ថ្នាំដោយសាប៊ូ និង ទឹក ។

ប្រើខ្សាច់ និង អាចម៍រណា រោយពីលើថ្នាំកំពប់ ហើយបោសសំអាតប្រមូលកើបដាក់ក្នុងធុង ដែលមានសញ្ញា ដើម្បីយកទៅកំទេចចោល ឬ បោះចោល ។

ថ្នាំដែលកំពប់ និង សំណល់ផ្សេងៗ ត្រូវតែជីកកប់ក្នុងជំរៅកន្លះម៉ែត្រឆ្ងាយពីអណ្តូង ឬ ផ្លូវទឹក។ ក្រដាសខ្ចប់ខាង ក្រៅត្រូវតែដុតចោលកណ្តាលវាលឆ្ងាយពីមនុស្ស និង សត្វ ។

## ៧.១១_ការបោះចោលធុងដាក់ថ្នាំ (Disposal of Empty Condition )

ក្រោយពេលលាយថ្នាំ ឬ បាញ់រួចហើយមិនត្រូវទុកធុងទទេចោល ដោយមិនបានយកទៅកំទេចចោល ។

របៀបបទសំរាប់យកសំបកធុងទៅចោល ឬកំទេចចោលដោយគ្មានគ្រោះថ្នាក់ :

-កំប៉ុង ឬ ធុងដែកត្រូវលាងសំអាត ចាក់ទម្លុះ និងកប់ចោល ។ ប៉ែកខាងលើរបស់សំបកធុងត្រូវស្ថិតក្រោមដីជំរៅកន្លះម៉ែត្រ

-សំបកធុងជាកែវ ត្រូវវាយបំបែក និង កប់ចោល

-កញ្ចប់ជាកាតុង ត្រូវដុតចោល នៅពេលដុតមិនត្រូវឈរហិតផ្សែងដុតនោះទេហើយត្រូវដេញក្មេងចេញអោយឆ្ងាយ

-បើសំបកធុងមិនអាចកំទេចចោល ឬ បោះចោលភ្លាមៗទេ ត្រូវលាងសំអាតវា និង ថែរក្សាទុកវា នៅកន្លែងមិនបណ្តោយអោយមានគ្រោះថ្នាក់

-មិនត្រូវប្រើសំបកធុងថ្នាំពុល សំរាប់ដាក់ស្បៀងអាហារឬទឹកផឹកទេ ពីព្រោះសំបកធុងនោះមិនអាចលាងអោយស្អាតថ្នាំទាំងស្រុងឡើយ

## ៧.១២_សំលៀកបំពាក់ការពារ (Protective Clothing )

ត្រូវស្លៀកសំលៀកបំពាក់ការពារ ដើម្បីបន្ថយជាអតិបរមានូវយថាហេតុ នៃការប្រឡាក់ស្បែក ដោយជាតិថ្នាំ។ បើអាចធ្វើបាន ត្រូវមានសំលៀកបំពាក់ពិសេសសំរាប់តែប្រើក្នុងពេលកាន់កាប់ថ្នាំ និង ដាក់ថ្នាំ ។ រាល់សំលៀកបំពាក់ការពារ ត្រូវតែលាងសំអាតអោយបានស្អាត ក្រោយពីបានប្រើប្រាស់រយៈពេលមួយថ្ងៃ ។

សូម្បីតែផ្លាកសញ្ញាមិនបានបញ្ជាក់ពីការស្លៀកពាក់ការពារក៏ដោយ ក៏ចាំបាច់ត្រូវស្លៀកពាក់ខោវែងអាវវែង ។ត្រូវពាក់មួកអោយបានល្អ ដែលមានហាមទូលាយដើម្បីការពារក្បាល និង ក ។

ស្រោមដៃកៅស៊ូ មានសារៈសំខាន់ណាស់ ហើយត្រូវមានជាប្រចាំក្នុងឃ្លាំង ឬហាងលក់ថ្នាំ ។ ត្រូវពាក់ស្រោមដៃជានិច្ចពេលប្រើប្រាស់ថ្នាំ ។ ស្រោមដៃរហែកអាចបណ្តាលអោយមានគ្រោះថ្នាក់ជាងការមិនពាក់ស្រោមដៃ ពីព្រោះខាងក្នុងស្រោមដៃ អាចប្រឡាក់សើមដោយថ្នាំ ។ ត្រូវពាក់វ៉ែនតាការពារភ្នែក ពាក់របាំងមុខរាល់ពេលបាញ់ថ្នាំលើដំណាំខ្ពស់ៗ ។

## ៧.១៣_វិធីបង្ការនៅពេលវាល់ និង ពេលលាយថ្នាំ (Precaution in Measuring and Mixing)

ត្រូវអានផ្លាកសញ្ញា ដើម្បីអោយដឹងកំរិតថ្នាំដែលត្រូវប្រើ សេចក្តីណែនាំអំពីការលាយនឹងឧបករណ៍សំរាប់បាញ់ថ្នាំ ឬ ដាក់ថ្នាំ ។

ត្រូវអនុវត្តតាមកំរិតដែលបានកំណត់ ទាំងថ្នាំ ទាំងទឹកដែលត្រូវលាយ ។ កំរិតខ្ពស់ពេក គ្មានប្រសិទ្ធភាពលើសទេ តែបើកំរិតទាបពេកធ្វើអោយបាត់ប្រសិទ្ធភាព ។

ថ្នាំគ្រាប់ និង ម្សៅម៉ដ្ឋ ដែលមិនបាច់លាយទឹក អាចយកទៅបាចផ្ទាល់ក្នុងស្រែចំការតែម្តង ដោយបាចនឹងដៃ ករណ៍បាចថ្នាំ ឬ ម៉ាស៊ីនបាចថ្នាំម្សៅ។

ចំណែកឯថ្នាំលាយទឹកស្រាប់ ក៏អាចត្រូវយកទៅបាញ់ផ្ទាល់តែម្តង ដោយគ្រាន់តែចាក់បញ្ចេញពីធុងថ្នាំបញ្ចូលទៅ

ក្នុងបំពង់បាញ់ថ្នាំតែប៉ុណ្ណោះ ។

ទឹកថ្នាំខាប់ដែលអាចរលាយយ៉ាងងាយស្រួលក្នុងទឹក ត្រូវបានវាល់តាមកំរិតចំនួនត្រឹមត្រូវ ហើយចាក់ចូលទៅក្នុងបំពង់បាញ់ថ្នាំ ។

ថ្នាំម្សៅអាចលាយជាមួយទឹកបន្តិច អោយក្លាយទៅជាម្សៅខាប់ៗ មុននឹងចាក់ចូលទៅក្នុងបាញ់ថ្នាំ ។ បន្ទាប់មកចាក់ទឹកចូលក្នុងធុងបាញ់ថ្នាំតាមកំរិតចំនួនកំណត់ រួចហើយលាយថ្នាំអោយបានសព្វ ។ មិនត្រូវដាក់ទឹកពេញបំពង់បាញ់ថ្នាំទេ យើងមិនត្រូវលាយថ្នាំច្រើនជាងតំរូវការបាញ់ក្នុងថ្ងៃជាមួយគ្នាដែរ ។

ប្រើប្រាស់ថ្នាំតាមកំរិតកំណត់ ហើយស្លៀកពាក់ការពារខ្លួនតាមកំណត់ ។ ត្រូវប្រើឧបករណ៍សមស្របដើម្បីវាល់និងលាយថ្នាំ ។

## ៧.១៤_ការបាញ់ថ្នាំក្នុងស្រែចំការដោយគ្មានគ្រោះថ្នាក់ (Safe Application in The Field )

-ពេលកំពុងបាញ់ មិនត្រូវបណ្តោយអោយមានអ្នកឈរមើល កុមារ ឬ សត្វធាតុក្នុងស្រែចំការឡើយ ។

-កុំទុកចោលថ្នាំពុលកសិកម្ម ឬ ឧបករណ៍ថ្នាំ ដោយគ្មានអ្នកឈរមើល

-មិនត្រូវបាញ់ថ្នាំបញ្ច្រាសខ្យល់ឡើយ មិនត្រូវបាញ់ថ្នាំពេលខ្យល់បក់បោកខ្លាំង ព្រោះវាបណ្តាលអោយចំហាយ ឬ ធុលីថ្នាំហើយផុតពីគោលដៅ

-មិនត្រូវបាញ់ថ្នាំពេលកំពុងក្តៅខ្លាំង ។ ការបែកញើសក្នុងពេលបាញ់ថ្នាំ អាចបណ្តាលអោយស្បែកយើងទទួលជាតិពុលបានយ៉ាងឆាប់ងាយ ។

-មិនត្រូវប្រើមាត់ផ្លុំក្បាលបិចដែលស្ទះ និង ត្រូវសំអាតក្បាលបិចដោយប្រើបំណែកឈើតូចៗ ឬដើមស្មៅ និងទឹក

-មិនត្រូវជក់បារី ឬ ចុកថ្នាំពេលកំពុងបាញ់ថ្នាំ ឬ លើកដាក់ថ្នាំ

-ត្រូវរង់ចាំយ៉ាងឆាប់រហ័ស ២៤ ម៉ោង មុននឹងដើរចូលទៅក្នុងចំការដែលបាញ់ហើយ

-ត្រូវមើលលើផ្លាកសញ្ញា ស្តីពីរយៈពេលអប្បបរមារបស់ឥទ្ធិពលថ្នាំ មុននឹងចូលទៅបាញ់ថ្នាំម្តងទៀត និងប្រមូលផល

-ត្រូវមានកម្មវិធីការងារច្បាស់លាស់ ដើម្បីកុំអោយមានសល់ទឹកថ្នាំលាយ រួចក្រោយពេលបាញ់ក្នុង ១ ថ្ងៃ បើមានសល់ទឹកថ្នាំ ត្រូវបន្តបាញ់ថ្ងៃស្អែកទៀតលើកលែងតែផ្លាកសញ្ញាលើដបថ្នាំ មិនអនុញ្ញាតអោយធ្វើ ។

-មិនត្រូវចាក់ទឹកថ្នាំនៅសល់ ឬ ទឹកលាងបំពង់ថ្នាំ ទៅក្នុងស្រះ ចរន្តទឹក ឬ លើមាត់ផ្លូវ

-លាងសំអាត និង ត្រូវពិនិត្យឧបករណ៍បាញ់ថ្នាំនៅពេលបញ្ចប់ការងារ

-ចាក់ទឹកលាងសំអាតឧបករណ៍បាញ់ថ្នាំនៅក្នុងរណ្តៅមួយក្នុងដី

## ៧.១៥_ការពុលថ្នាំ និង ជំនួយសង្គ្រោះបន្ទាន់ (Poisoning and First Aid )

-ការបង្ការការពុល វាងាយស្រួលជាងការព្យាបាល ដូចនេះត្រូវកាន់កាប់ថ្នាំពុលកសិកម្ម ដោយប្រុងប្រយ័ត្នជាទី

បំផុត

-ក្នុងការព្យាបាលជំងឺដោយប្រឡាក់ថ្នាំ ឬ លេបថ្នាំចូលត្រូវចាត់ការអោយឆាប់រហ័សជាទីបំផុត

-ត្រូវហៅវេជ្ជបណ្ឌិត ឬ ដឹកអ្នកជំងឺទៅមន្ទីរពេទ្យជាបន្ទាន់

-ត្រូវបង្ហាញដល់វេជ្ជបណ្ឌិត នូវផ្លាកសញ្ញាលើសំបកថ្នាំ ហើយជំរាបគាត់ តើការពុលនោះតាមរបៀបណា ដោយលេបចូល ដកដង្ហើមចូល ឬប៉ះពាល់ស្បែក

-មានតែសមត្ថកិច្ចទេដែលអាចអោយថ្នាំបន្សាបបាន

-សញ្ញានៃការពុលថ្នាំស្រាលៗមាន : ជំងឺវិលមុខ ឈឺក្បាល រាគ សង្កៀរស្បែក ស្បែក ច្រមុះ

-សញ្ញាពុលថ្នាំខ្លាំង : ឈឺពោះ ជីពចរដើរលឿន លំបាកដកដង្ហើម ញ័រញាក់ ក្អួតចង្អោរ ។ល។

ពេលរង់ចាំជំនួយសង្គ្រោះពីពេទ្យ យើងអាចជួយអ្នកជំងឺដូចតទៅ :

-ដោះសំលៀកបំពាក់ប្រឡាក់ថ្នាំចេញ ហើយលាងសំអាតខ្លួនប្រាណ និង សក់ដែលប្រឡាក់ថ្នាំ

-ទឹកថ្នាំ ឬ ម្សៅថ្នាំដែលខ្ទាតចូលភ្នែក អាចជ្រាបចូលបានយ៉ាងឆាប់រហ័ស ត្រូវលាងសំអាតជាបន្ទាន់ដោយប្រើទឹកស្អាត ។ បន្តលាងសំអាតភ្នែកយ៉ាងតិចបំផុត ១០ នាទី

-ពេលសង្ស័យមានការពុល ដាច់ខាតមិនត្រូវអោយអ្នកផឹកស្រា ឬ ទឹកដោះគោ

-ត្រូវទុកដាក់អ្នករងគ្រោះអោយបានស្រួល និង ស្ងប់ស្ងាត់ ដើម្បីទុកឱកាសអោយអ្នករងគ្រោះអាចជាឡើងវិញបាន

-ក្រោយពេលបានជារួចហើយ អ្នករងគ្រោះមិនត្រូវប៉ះពាល់ថ្នាំក្នុងរយៈកាលច្រើនសប្តាហ៍ ។ ផ្ទុយទៅវិញ គេនឹងពុលខ្លាំងជាងមុនទៅទៀត ។

## ៧.១៦_បញ្ហាចោទក្នុងការប្រើប្រាស់ថ្នាំពុលកសិកម្ម

-ថ្នាំពុលកសិកម្មជាអ្វី ?

ក-កត្តាចង្រៃ

ខ-ឈ្មោះរួមរបស់ថ្នាំកសិកម្ម

គ-ភាពពុលរបស់ថ្នាំកសិកម្ម

ឃ-ចំណែកថ្នាក់ភាពពុលតាម WHO

**LD$_{50}$ for the rate mg/kg b.w**

| WHO Class. | Oral | | Dermal | |
|---|---|---|---|---|
| | Solid | Liquid | Solid | Liquid |
| Ia | <5 | <20 | <10 | <40 |
| Ib | 5-50 | 20-200 | 10-100 | 40-400 |
| II | 50-500 | 200-2000 | 100-1000 | 400-4000 |
| III | >501 | >2001 | >1001 | >4001 |

Ex-
Ia-Alumium phosphate
Ib-Zinc phosphide
II- Diazinon 2,4 D
III-Dimethylamine

## ៧.១៧_ការលក់ថ្នាំ (Sales):

អ្នកលក់ថ្នាំត្រូវផ្តល់ពត៌មានអំពីការប្រើប្រាស់ថ្នាំពុលកសិកម្ម ដល់អ្នកទិញអោយបានសមស្រប ។ អ្នកទិញមានសិទ្ធពិនិត្យយ៉ាងផ្ចិតផ្ចង់ និង ប្រកែកមិនយកនូវកញ្ចប់ថ្នាំណាដែលរហែក គ្មានសញ្ញាសំគាល់ ឬ ហួសពេលប្រើប្រាស់ ។

-ណែនាំអោយអ្នកទិញទុកដាក់ថ្នាំអោយបានត្រឹមត្រូវ

-មិនត្រូវយកដបថ្នាំ កំប៉ុង ដាក់ចំណីអាហារ ឬ ទឹកផឹក

-ទុកដាក់ឆ្ងាយពីចំណីអាហារ និង ទឹកប្រើប្រាស់

-ទុកដាក់ថ្នាំផុតពីដៃក្មេង យកល្អចាក់សោរទុកក្នុងទូរ ឬ កេស

-មិនត្រូវយកគ្រាប់ដែលលាយថ្នាំហើយមកបរិភោគឡើយ

## ៧.១៨_ការប្រើប្រាស់ ថែទាំ និង ជួសជុលឧបករណ៍ដាក់ថ្នាំ

(The Use Maintenance and Repair of Application Equipment)

មុននឹងដាក់ថ្នាំ អ្នកកាន់បំពង់បាញ់ថ្នាំ និង កសិករត្រូវទទួលការបំពាក់បំប៉នដូចតទៅ :

-ត្រូវពិនិត្យឧបករណ៍ វែកងមានការលេចទឹកថ្នាំ ឬ ដំណើរការមិនស្រួល

-ទឹកថ្នាំមានពេញបំពង់ឬទេ កំលាំងសំពាធយ៉ាងណា

-ការវាល់ថ្នាំត្រឹមត្រូវតាមកំរិត និង ចំណុះឬទេ

-ការបាញ់ថ្នាំប្រកបដោយសុវត្ថិភាព និង ប្រសិទ្ធភាព

-ការលាងសំអាត និងថែរក្សាឧបករណ៍ និង គ្រឿងបន្លាស់

មិនត្រូវប្រើប្រាស់បំពង់បាញ់ថ្នាំដែលលេច និងដំណើរការមិនស្រួល

-មិនត្រូវប្រើឧបករណ៍មានគុណភាពអន់ : ឧបករណ៍អន់អាចបណ្តាលអោយមានគ្រោះថ្នាក់

-មិនត្រូវប្រើប្រាស់ដែកគោល ដើម្បីដុសសំអាតតំរង ឬ ក្បាលបិចដែលស្ទះ ពីព្រោះការនេះ អាចធ្វើអោយខូច

ឧបករណ៍ និង ប្រើប្រាស់ថ្នាំហួសកំរិត ព្រមទាំងវិសាលភាពបាញ់ថ្នាំមានកំរិតទាប ។ ប្រើប្រាស់ប្រដាប់ទន់ៗ ត្រូវយកគ្រឿងបន្លាស់ទៅតាមខ្លួន

-ក្រោយពេលបាញ់ថ្នាំរួចហើយ ត្រូវពិនិត្យឧបករណ៍បាញ់ថ្នាំឡើងវិញ

## ៧.១៩_រូបមន្តថ្នាំសំលាប់សត្វល្អិត

### ក_រូបមន្តថ្នាំគ្រាប់ និង ម្សៅ :

$$PM = \frac{RR \times A \times 100}{a.i\ \%}$$

RR -បទដ្ឋានប្រើប្រាស់ គិតជា គ.ក្រ នៃបរិមាណធាតុសុទ្ធ/ហិកតា

PM -បរិមាណថ្នាំពុល គិតជា គ.ក្រ/ហិកតា

A -ផ្ទៃដី គិតជា ហិកតា

a.i % -ភាគរយនៃធាតុសកម្ម

### ខ_រូបមន្តថ្នាំទឹក :

$$PM = \frac{RR \times V \times A}{a.i\ \%}$$

RR - បទដ្ឋានប្រើប្រាស់ គិតជា ភាគរយ នៃ ធាតុសកម្ម/ហិកតា

PM - បរិមាណថ្នាំពុល គិតជា លីត្រ /ហិកតា

V - មាឌនៃសូលុយស្យុង គិតជា លីត្រ /ហិកតា

a.i % - ភាគរយនៃធាតុសកម្ម

## ៧.២០_ការប្រើប្រាស់ថ្នាំពុលសំរាប់ការពារ និង កំចាត់

### ក_ការការពារឬសំលាប់មេរោគ :

-ជ្រលក់ឬសកូនរុក្ខជាតិទៅក្នុងល្បាយ Bordeaux រយៈពេល ៥ នាទី ហើយលាងសំអាតដោយទឹកធម្មតា មុនយកទៅដាំ

-ប្រើទឹកក្ដៅនៅសីតុណ្ហភាព ៤៣.៣ អង្សាសេ រយៈពេល ៣-៦ នាទី

-ក្នុងករណីថ្នាលបណ្ដុះកូនមានជំងឺរលួយ ត្រូវធ្វើការកំចាត់ដោយប្រើសូលុយស្យុងទឹក Carbathion ៤០ %

( ៨ លីត្រល្បាយ/ម $^២$ ) ឬ Pentachlor nitrobentazole ៥0 %  ១00-១២0 g/ម $^២$  ១0  ថ្ងៃមុនសាប

**ខ-ការពារជំងឺ :**

-ជំងឺហូរជ័រ ឬ រលួយពណិត្នោត :

បណ្តាលមកពីផ្សិត ឈ្មោះ Phytophtora កើតមានឡើងនៅកន្លែងសំណើមខ្ពស់ ហើយកើតមាននៅលើដើម ស្លឹក ឫស ក្តិប ផ្លែ គេប្រើ Bordeaux 1 %

-ជំងឺ រលួយគល់ ឬ ឫស : ប្រើ Metalaxyl បាញ់ក្នុងកំរិត ១៥ ក្រ/២0 ល ទឹក

-ជំងឺប្រេះសំបកចេញជ័រ: ប្រើ Metalaxyl លាប ក្នុងកំរិត ៨0-១00 ក្រ/ល ទឹក ឬ ថ្នាំយូថា (Utar) មកលាប តែម្តង

**គ-សត្វចង្រៃ :**

-ពីងពាងក្រហម : ប្រើ Phosdrin ៦ ស្លាបព្រា/ ១៧ លីត្រ ទឹក

-ស្រឹង : ប្រើ Sevin ៦ ស្លាបព្រា/ ១៧ លីត្រ ទឹក

-ក្រា និង ចៃ : ប្រើ Malathion ៨ ស្លាបព្រា/ ១២ លីត្រ ទឹក

-ដង្កូវស៊ីផ្លែ : ប្រើ Diazinan ២ លីត្រ/ហ.ត

-ដង្កូវស៊ីរូងកួរ : ប្រើ Monocrotophos ២ លីត្រ , Carbaryl ២-៥ គ.ក្រ

-ដង្កូវហ្វូង : ប្រើ Malathion ២ លីត្រ/ហ.ត

-ដង្កូវស៊ីរូងដើម : ប្រើ Carbaryl ២ គ.ក្រ/ហ.ត/១00 លីត្រ

# មុខងារ និង សារៈសំខាន់នៃជីជាតិ

## ១-កាបូន អ៊ីដ្រូសែន និង អុកស៊ីសែន

-ធាតុទាំងនេះទទួលបានពីខ្យល់ និង ដី ក្នុងទំរង់ជាកាបូនឌីអុកស៊ីត និង ទឹក

-ជាសមាសធាតុនៃប្រូតូប្លាស និង ជាសមាសធាតុសរីរាង្គជាច្រើននៅក្នុងរុក្ខជាតិ

## ២-អាសូត

**២.១-អក្សរកាត់ N**

**២.២-ប្រភព :**

-អ៊ីយ៉ុងនីត្រាត នៅក្នុងដី អំបិលនីទ្រីត និង អាម៉ូនីញ៉ាក់

-នៅក្នុងដើមរុក្ខជាតិ និង ស្លឹក នៅក្នុងឫស ឧ. ពពួកសណ្តែក

-ក្នុងជាលិកាសត្វ

**២.៣-រុក្ខជាតិដែលមានអាសូតច្រើន ដូចជា :**

-សណ្តែកបាយ សណ្តែកខ្មោច ទន្រ្ទានខេត្ត អង្កាដី អង្កាញ់ ស្នោ......

**២.៤-ជាតិអាសូតក៏មាននៅក្នុង :**

-ទឹកនោម អាចមប្រជៀវ កាកសណ្តែក លាមកគោ ក្របី ជ្រូក មាន់ ទា ចៀម ពពែ សេះ

**២.៥-មុខងាររបស់អាសូត :**

-ជំនួយធ្វើអោយដើម និង ស្លឹកនៃរុក្ខជាតិដុះលូតលាស់បានល្អ ឆាប់រហ័ស និង ជួយ អោយទិន្នផលខ្ពស់

-ចំពោះស្រូវធ្វើអោយបែកគុម្ពច្រើន ( ប្រើច្រើនចំពោះពូជស្រូវក្នុងស្រុក ធ្វើអោយដើមខ្ពស់ត្រូវទ្រោម ឬដួលធ្វើ អោយទិន្នផលចុះទាប )

-ម្យ៉ាងទៀតការដាក់ជីជាតិ N ច្រើននាំអោយផ្លែរុក្ខជាតិក្រទុំ

-ចំពោះស្រូវវិញគឺទុំមិនស្រុះគ្នា ដែលគេនិយមហៅថា ស្រូវបណ្តើរកូន

-ចំពោះដំណាំបន្លែយកស្លឹក ត្រូវការចាំបាច់ជី N ព្រោះជាតិ N មានមុខងារសំខាន់ក្នុងកាបង្កើនស្លឹក

**២.៦-រោគសញ្ញាខ្វះអាសូត :**

-ស្លឹកមានពណ៌លឿង ស្លឹកផ្នែកខាងក្រោមធ្លាក់ចុះ កើតនៅលើស្លឹកចាស់មុន

**២.៧-រោគសញ្ញាលើស :**

-មានលូតលាស់របស់សរីរាង្គលូតលាស់ខ្លាំង និង សរីរាង្គបន្តពូជខ្សោយ

-ធ្វើអោយរុក្ខជាតិងាយទទួលរងនូវការបំផ្លាញពីសំណាក់សត្វល្អិត និង ជំងឺ

-វាធ្វើអោយដើមទន់ ស្លឹកពណ៌បៃតងចាស់ និង សំបូរទឹកដម ដោយនីត្រូសែនដែលលើសរារាំងដល់ការលូតលាស់

របស់កោសិកាមេកានិច ដូចជា Sclerenchyma

**២.៨-ជីអាសូតនៅក្នុងរុក្ខជាតិដែលរុក្ខជាតិស្រូបបាន**

ពពួកសំណើក ទន្រ្ទានខេត្ត លាមកសត្វទៅដាក់ធ្វើជី មិនអាចអោយរុក្ខជាតិស្រូបយកបានភ្លាមទេ លុះត្រាធម្ម-ជាតិទាំងនោះ ពុករលួយប្រែក្លាយទៅជា អាសូតនីទ្រិច ទើបរុក្ខជាតិអាចស្រូបបានឆាប់រហ័ស

**២.៩-ជីអាសូតនៅក្នុងជីគីមី**

-ស៊ុលហ្វាតអាម៉ូនីញ៉ូម ( ប្រើធ្វើអោយដីជូ ) ប្រើលើបន្លែ N=20-21 %

-អ៊ុយរ៉េ N=45-46 % ប្រើបានលើដីគ្រប់ប្រភេទ និង គ្រប់ដំណាំ

## ៣_ហ្វូស្វ័រ

**៣.១-អក្សរកាត់ P**

**៣.២-ប្រភព :**

-នៅក្នុងរុក្ខជាតិ ផេះឆ្អឹង ផេះឈើ

-អាចមប្រជៀវ លាមកគោ ក្របី ជ្រូក មាន់ ទា ម្សៅត្រី កាកសណ្តែក កាកសំណល់ពីផ្ទះបាយ

-នៅក្នុងរ៉ែ នៅភ្នំទូកមាស ភ្នំសំពៅ

**៣.៣-មុខងារ :**

-ជំនួយអោយរុក្ខជាតិដុះលូតលាស់បានល្អ ឆាប់ដុះឫស ដើមរឹងមាំ ធាត់ធំ ផ្កា ផ្លែបានច្រើននិង អោយទិន្នផលខ្ពស់ ។ បើដំណាំស្រូវវិញធ្វើអោយផ្លែច្រើន គ្រាប់ពេញល្អ មិនសូវមានសំដីធន់នឹងការដួលរលំ ហើយធន់នឹងជំងឺ

-ធ្វើអោយផ្លែរុក្ខជាតិឆាប់ទុំ

-ចំពោះឈើហូបផ្លែ ធ្វើអោយផ្លែច្រើន ហើយរស់ជាតិផ្អែមឆ្ងាញ់

-ជាយាន និង ជាថាមពលសំរាប់នាំជាតិផ្សេងៗ ក្នុងការស្រូបយកជីជាតិពីក្នុងដីផ្តល់ដល់ស្លឹកដើម ផ្កា ផ្លែ ។

**៣.៤-រោគសញ្ញាខ្វះហ្វូស្វ័រ :**

-ការលូតលាស់យឺត និង ស្លឹកមានពណ៌បៃតងចាស់ ទងស្លឹក ផ្លែ និង ស្លឹកធ្លាក់ចុះ

**៣.៥-ហ្វូស្វ័រ នៅក្នុងរុក្ខជាតិ**

-ដើមខ្ចីនៃរុក្ខជាតិ

**៣.៦-ជីជាតិហ្វូស្វ័រនៅក្នុងជីគីមី :**

-ជីហ្វូស្វាតទូកមាស P = 20 % ជីស៊ុបពែហ្វូសស្វាត P = 18 %

## ៤_ប៉ូតាស្យូម

**៤.១-អក្សរកាត់ K**

**៤.២-ប្រភពមាននៅក្នុង :**

-ផេះឈើ ជាពិសេសផេះដើមខ្ចី សំបកផ្លែគ កំពុកដើមចេក ផេះអង្កាម ក្នុងដី

-ក្នុងលាមកគោ ក្របី មាន់ ទា ......

**៤.៣-មុខងារ :**

-ធ្វើអោយរុក្ខជាតិដុះលូតលាស់បានល្អ

-ផ្លែដាក់គ្រាប់ពេញ

-បើរុក្ខជាតិយកមើម K ធ្វើអោយមើមច្រើន និង ធំល្អ ហើយមានទំងន់ធ្ងន់

-ជួយសំរួលដល់ការស្រូបយកជីជាតិ N

-ជួយរុក្ខជាតិធន់ទ្រាំនឹងការរាំងស្ងួត

-ជួយរុក្ខជាតិធន់ទ្រាំនឹងជំងឺ

-បើដំណាំស្រូវ ការប្រើជីជាតិ N និង P គេអាចកែសន្ទូង ដែលយើងពិនិត្យទៅឃើញថា មានជាតិ N ច្រើន ហួសកំនត់សេចក្តីត្រូវការរបស់ដើមស្រូវ ហើយជីនេះអាចជួយមិនអោយស្រូវដួល ឬ ទ្រោម

**៤.៤-ដំណាំដែលត្រូវការជាតិ :**

ក/ដំណាំដែលត្រូវការជីជាតិ K ចំនួនច្រើនមានដំណាំ :

-យកមើម : ដំឡូង ដំណាំស្ពៃ ប៉េងប៉ោះ ដំណាំអំពៅ ម្នាស់ ចេក ដូង ស្លា

ខ/ដំណាំត្រូវការជី ជាតិ K មធ្យម :

-សណ្តែកដី ល្ហុងខ្មែរ ល្ង

**៤.៥-ជីប៉ូតាសនៅក្នុងដើមរុក្ខជាតិ :**

-ផ្នែកនៅខ្ចី

**៤.៦-ជីប៉ូតាសនៅក្នុងជីគីមី :**

-ស៊ុលហ្វាតប៉ូតាសមាន : 48 % ប៊ីកាបូណាតមាន : 46 % និង ក្លរៀប៉ូតាស្យូមមាន : 60 %

<u>ចំណាំ :</u> K ប្រើបានដំណាំគ្រប់មុខ លើកលែងតែដំណាំថ្នាំជក់

## ៥-កាល់ស្យូម

**៥.១-អក្សរកាត់ Ca**

-តាមធម្មតាជាតិ គេដាក់គ្រាន់តែជួយកែលំអជីជូ (ដីអាស៊ីត) អោយ pH ឡើង

-ជួយរក្សាទំរង់ដី

-ចំពោះការលូតលាស់នៃរុក្ខជាតិ កាល់ស្យូមមានមុខងារតិចតួច

**៥.២-ការកែប្រែទំរង់ដីដោយប្រើជាតិ កំបោរ :**

-ដីស្អិតហាប់អោយទៅជាដីផុស ងាយដល់ការចាក់ឬសរបស់រុក្ខជាតិ

-ជួយការពារជាតិពុលដូចជា Cu , Na , Mg .....

-ជីអាចកែដីមានជាតិកាល់ស្យូមច្រើនបាន គឺជីធម្មជាតិមានឧស្ម័នកាបូនិច

**៥.៣-រោគសញ្ញាខ្វះខាត :**

-Clorosis កើតមាននៅជិតគែមស្លឹក ជាពិសេសចំពោះស្លឹកខ្ចី

-ការលូតលាស់ផ្នែកខាងចុងនៃឫស និង ដើមថយចុះ

-ការបង្កើតគ្រាប់ក៏ ថយចុះដែរ

## ៦-ម៉ាញ៉េស្យូម

**៦.១-អក្សរកាត់ Mg**

-ជីជាតិម៉ាញ៉េស្យូមមាននៅក្នុងក្លូរ៉ូភីល និង មានមុខងារសំខាន់នៅក្នុងជីវិតនៃរុក្ខជាតិ

**៦.២-រោគសញ្ញាខ្វះជាតិម៉ាញ៉េស្យូម :**

-គេសង្កេតឃើញនៅលើដីជូរ ឬ ដីខ្សាច់ភាគច្រើន

-កាលណាវាចេញរោគសញ្ញាខ្វះជាតិម៉ាញ៉េស្យូម គឺគេដាក់ជីដែលមានជាតិម៉ាញ៉េស្យូមទៅតាមធាតុរបស់ដី :

-ដីអាស៊ីត : កំបោរម៉ាញ៉េស្យូម

-ដីអាល់កាឡាំង : ស៊ុលហ្វាតម៉ាញ៉េស្យូមដោយគេលាយជាមួយទឹកយកទៅបាញ់នើស្លឹកតែម្តង

## ៧-ដែក

**៧.១-អក្សរកាត់ Fe**

**៧.២-មុខងារ :**

-បង្កបង្កើតក្លូរ៉ូភីល

**៧.៣-រោគសញ្ញាខ្វះជាតិដែក :**

-អវត្តមានដែកធ្វើអោយស្លឹកខ្ចីបំផ្លាញមុនស្លឹកចាស់

-ពេលខ្លះបំផ្លាញលើមែកមួយ ឬ ស្លឹកមួយប៉ុណ្ណោះ

-ការខ្វះជីជាតិដែកលុះត្រាតែមានជាតិកំបោរលើសចំនួន ឬ ជាតិហ្វូស្វាត ដូច្នេះត្រូវដាក់ជីធម្មជាតិ

## ៨-ម៉ង់កាណែស

**៨.១-អក្សរកាត់ Mn**

**៨.២-រោគសញ្ញាខ្វះជាតិ ម៉ង់កាណែស :**

-ផ្ទៃស្លឹកមានចំណុចពណ៌ត្នោត និង ប្រផេះ

-ការខ្វះខាតនេះកំរកើតមាននៅលើដីអាស៊ីតណាស់ មានតែនៅលើដីអាល់កាឡាំង

## ៩_ទង់ដែង

### ៩.១-អក្សរកាត់ Cu

### ៩.២-ប្រភព :

-ដី រុក្ខជាតិ

### ៩.៣-មុខងារ :

-សំរាប់ដំណើររស្មីសំយោគ ផលិតអុកស៊ីសែននៅក្នុងដំណើររស្មីសំយោគ

-ធ្វើអោយសារាយ និងផ្សិតពុល( ទង់ដែងស៊ុលហ្វាត) គេប្រើសំរាប់ការពារការដុះលូតលាស់របស់សារាយនៅក្នុង ស្រះត្រី អាងហែលទឹក និង ផ្ទុកទឹកសំរាប់ផឹក ។

### ៩.៤-រោគសញ្ញាខ្វះជាតិទង់ដែង :

-លឿងចុងស្លឹកខ្ចីៗ បន្ទាប់មានចំណុចត្នោតកើតឡើង

-ចំពោះពោតធ្វើអោយស្លឹកមានឆ្នូតពណ៌ប្រផេះ

## ១០_សង្កសី

### ១០.១-អក្សរកាត់ Zn

### ១០.២-រោគសញ្ញាខ្វះជាតិសង្កសី :

-ធ្វើអោយកើតជំងឺរួញស្លឹក បំផ្លាញស្លឹកផ្នែកខាងចុង និង គែមស្លឹកមានពណ៌លឿង

-ចុងមែកងាប់ ឬសដុះលូតលាស់មិនធម្មតា និង ផ្លែមានទំហំតូច

## ១១_ម៉ូលីដែន

### ១១.១-អក្សរកាត់ Mo

### ១១.២-មុខងារ :

-ធ្វើអោយងាយស្រួលដល់ការស្រូបយកជាតិអាសូតពីក្នុងបរិយាកាស ដោយសារពកឬសរបស់ សណ្តានលេគុយមីណឺ

### ១១.៣-រោគសញ្ញាខ្វះជាតិម៉ូលីដែន :

-ធ្វើអោយនីត្រាតកើនឡើងក្នុងរុក្ខជាតិ នាំអោយការសំយោគប្រូតេអ៊ីនថយចុះ

-ការលូតលាស់ត្រូវឈប់

-ពកឬសនៃពួកសណ្តែកលូតលាស់យឺត

### ១១.៤-រោគសញ្ញាលើសជាតិម៉ូលីដែន :

-ធ្វើអោយរុក្ខជាតិពុលខ្លាំង

**១២_ក្លរ**

**១២.១-អក្សរកាត់** Cl

**១២.២-រោគសញ្ញាខ្វះជាតិក្លរ :**

-ធ្វើអោយចុងស្លឹកស្ងួត ឬសក្រិន

**១៣_ប៊រ**

**១៣.១-អក្សរកាត់** B

**១៣.២-ប្រភព :** ក្នុងដី

**១៣.៣-មុខងារ :**

-វាបង្កើនភាពរលាយ និង ចលនារបស់កាល់ស្យូម

-ដើរតួរសំខាន់ក្នុងមេតាប៉ូលីសប្រេង និង កាបូនអ៊ីដ្រាត មានឥទ្ធិពលដល់ការសំយោគប្រូតេអ៊ីន

-កំណត់ការស្រូបយកទឹកដោយបង្កើត ប៊ុបទីន ក្នុងភ្នាសកោសិកា

**១៤_ស្ពាន់ធ័រ**

**១៤.១-អក្សរកាត់** S

**១៤.២-ប្រភព :**

-ក្នុងដី និង រុក្ខជាតិ នៅរួមជាមួយជាតិប្រូតេអ៊ីន

**១៤.៣-មុខងារ :**

- ហើយជាតិនេះធ្វើអោយរុក្ខជាតិងាយស្រួលដកដង្ហើម

**១៥_សូដ្យូម**

**១៥.១-អក្សរកាត់** Na

**១៥.២-ប្រភព :**

-ជាតិនេះចាំបាច់ខ្លះសំរាប់រុក្ខជាតិខ្លះដូចជា កប្បាស ដូង

-បើមានជាតិសូដ្យូមលើសធ្វើអោយដីមានទំរង់មិនល្អ

## ដីនៅកម្ពុជា

**១-ល្បប់ទន្លេមេគង្គ** (Alluvial Soils ) :

-ជាប្រភេទដីល្បប់-ឥដ្ឋ ជាដីមានជីជាតិល្អ លិចទឹករាល់ឆ្នាំ និងមានរស់ជាតិជូរ

-ស្រទាប់ដីកសិកម្មមានជំរៅពី ១០-២០ ស.    pH = ៤,៥-៦,៥

-មានផ្ទៃដីចំនួន ១.៧០៦.៤០០ ហ.ត  អាចដាំដុះបាន ១.០២៣.៨០០ ហ.ត

-ដាំដំណាំស្រូវប្រដេញទឹក  ទិន្នផល ១,០-១,២ ត/ហ.ត

-តំឡើងទិន្នផលស្រូវដោយប្រើ :

-ចាត់ចែងទឹកឱ្យបានត្រឹមត្រូវ

-ជីស្រស់ ជីហ្វូស្វាត និង ជីប៉ូតាស

-មិនត្រូវប្រើប្រាស់ជីដែលមានអ៊ីយ៉ុង $SO_4^{-2}$

-គេអាចដាំដំណាំ ថ្នាំជក់  ឪឡឹក  សណ្តែក........

**២-ល្បប់ពណ៌ត្នោតតាមមាត់ទន្លេ** (Brown Alluvial Soils ) :

-ជាប្រភេទដីខ្សាច់-ល្បប់ ទៅឥដ្ឋ-ល្បាប់  ជាដីមានជីជាតិល្អ  មិនជាំទឹក

-ស្រទាប់ដីកសិកម្មមានជំរៅពី ១០-២០ ស.ម    pH = ៥-៦,៨

-មានផ្ទៃដីចំនួន ២៧៦.៤០០ ហ.ត  អាចដាំដុះបាន ៥៥.៣០០ ហ.ត

-អាចធ្វើប្រពលវប្បកម្មបង្កើនរដូវដោយ :

-ប្រើប្រាស់ដីឱ្យបានត្រឹមត្រូវ

-ប្រើប្រាស់ពូជសំរាំង

-ការពារទប់ទល់នឹងទឹកឡើង

-ជីស្រស់ ជីហ្វូស្វាត និង ជីប៉ូតាស

-គេអាចដាំដំណាំ ហូបផ្លែ  ពោត  អំពៅ  ថ្នាំជក់  ឪឡឹក  សណ្តែក........

**៣-ល្បប់ជុំវិញបឹងទន្លេសាប** (Lacustrine Alluvial Soils ) :

-ជាប្រភេទដី ឥដ្ឋ-ខ្សាច់ ឬ ខ្សាច់-ល្បប់  ជាដីមានជីជាតិល្អ

-ស្រទាប់ដីកសិកម្មមានជំរៅពី ២-៤ ម    pH = ៥,៥-៧,២

-មានផ្ទៃដីចំនួន ១.០៣៧.៣០០ ហ.ត  អាចដាំដុះបាន  ២៣៣ .៤០០ ហ.ត

-អាចធ្វើស្រូវឡើងទឹកដោយប្រើជីហ្វូស្វាត

-ជាប្រភេទព្រៃលិចទឹក

## ៤_ដីក្រហមបាសាល់ Latosols

-ជាប្រភេទដី ឥដ្ឋ ទៅ ដីឥដ្ឋ-ល្បប់ ជាដីមានជីជាតិល្អ

-ស្រទាប់ដីកសិកម្មមានជំរៅពី ១0 pH = ៥,៥-៦,៨

-មានផ្ទៃដីចំនួន ៧១២.៣00 ហ.ត អាចដាំដុះបាន ៣៥៦.២00 ហ.ត

-ជាដីដាំដំណាំកៅស៊ូ និង ព្រៃចំរុះ (ក្នុងករណីដែលគ្មានការដាំដុះ )

-ដំណាំស្រូវភ្នំ ចេក ពោត សណ្តែក ដំណាំយកផ្លែ តែ កាហ្វេ........

-ជាដីត្រូវការជីហ្វូស្វាត យ៉ាងខ្លាំង

-ការពារហូរច្រោះ ភ្លើងឆេះព្រៃ

## ៥_ដីខ្មៅបាសាល់ Basaltic Regurs

-ជាប្រភេទដី ឥដ្ឋ សើមហើយរឹង

-ស្រទាប់ដីកសិកម្មមានជំរៅពី ២0-៤0 ស.ម pH = ៦,0-៨,0

-មានផ្ទៃដីចំនួន ៦៥៧.000 ហ.ត អាចដាំដុះបាន ៩៨.000 ហ.ត

-ជាដីដាំដំណាំកប្បាស ក្រចៅ ពោត សណ្តែកបាយ អំពៅ ម្នាស់ និងប្រយ័ត្នចំពោះ ដំណាំស្រូវនូវជាតិដែក ហើយ គេអាចដាំដំណាំបន្លែនៅលើដីដែលទើបរានរួច

## ៦_ដីជាំទឹកពណ៌ត្នោតខ្ចី Brown Hydromorphics

-ជាប្រភេទដី ឥដ្ឋ ឬ ខ្សាច់ ដីល្បប់ទៅខ្សាច់ ជាដីមានជីជាតិល្អ

-ស្រទាប់ដីកសិកម្មមានជំរៅពី ២៥ ស.ម pH = ៥,0-៦,៨

-មានផ្ទៃដីចំនួន ៦៧0.១00 ហ.ត អាចដាំដុះបាន ៤0២.១00 ហ.ត

-ជាដីដាំដំណាំបានផលខ្ពស់បង្គួរ ១,៦ ត/ហ.ត ដោយគ្មានប្រើជី បើប្រើជីត្រឹមត្រូវអាចឈានដល់ ៣,៦ ត/ហ.ត

-តំបន់ដីខ្ពស់គេច្រើនដាំដំណាំយកផ្លែ ពពួកសណ្តែក និង ដំណាំឧស្សាហកម្ម

## ៧_ដីជាំទឹកដាំដុះ (Cultural hydromorphics ) :

-ជាប្រភេទដីល្បប់-ខ្សាច់ ទៅ ឥដ្ឋ ជាដីពុំសូវមានជីជាតិល្អ

-ស្រទាប់ដីកសិកម្មមានជំរៅពី ១៥-២៥ ស.ម pH = ៤,២-៥,៣

-មានផ្ទៃដីចំនួន ១.២៨៩.៦០០ ហ.ត អាចដាំដុះបាន ១.១៦.៦០០ ហ.ត

-ដាំដំណាំស្រូវ ទិន្នផល ០,៨-១,០ ត/ហ.ត

-បើប្រើជីកំប៉ុស្តិ អាចផ្តល់ទិន្នផល ១,២-១,៨ ត/ហ.ត

-តំឡើងទិន្នផលស្រូវដោយប្រើ :

-ជីកំប៉ុស្តិ

-ពពួកសណ្តែក

-ក្រៅពីស្រូវគេអាចដាំដំណាំ ថ្នាំជក់ និង ឪឡឹក......

## ៨_ដីជាំទឹកពណ៌ប្រផេះ (Grey hydromorphics) :

-ជាប្រភេទដី ឥដ្ឋ-ល្បប់ ទៅ ឥដ្ឋ ជាដីពុំសូវមានជីជាតិល្អ

-ស្រទាប់ដីកសិកម្មមានជំរៅពី ១០-២០ ស.ម pH = ៤,០-៥,៧

-មានផ្ទៃដីចំនួន ១.៧២៥.២០០ ហ.ត អាចដាំដុះបាន ៣៤៥ .០០០ ហ.ត

-ដាំដំណាំស្រូវប្រដេញទឹក ទិន្នផល ០,៨-១,៤ ត/ហ.ត

-តំឡើងទិន្នផលស្រូវដោយប្រើ :

-ចាត់ចែងទឹកឱ្យបានត្រឹមត្រូវ

-ជីស្រស់ ជីហ្វូស្វាត និង ជីប៉ូតាស

-មិនត្រូវប្រើប្រាស់ជីដែលមានអ៊ីយ៉ុង $SO_4^{-2}$

-គេអាចដាំដំណាំ ហូបផ្លែ សណ្តែក........

## ៩_ដីក្នុងតំបនជាំទឹកតាមស្រទាប់ (Planosols ) :

-ជាប្រភេទដី ខ្សាច់-ល្បប់ ទៅ ល្បប់ ជាដីមានជីជាតិល្អមធ្យម

-ស្រទាប់ដីកសិកម្មមានជំរៅពី ៣០ ស.ម pH = ៥-៧

-មានផ្ទៃដីចំនួន ១៦៦.៦០០ ហ.ត អាចដាំដុះបាន ៨.៣០០ ហ.ត

-ដាំដំណាំស្រូវ

-ជាព្រៃត្រូពិចចំរុះគ្នា

## ១០_ដីប្រមូលផ្តុំតាមឆ្នេរសមុទ្រ (Coastal complex ) :

-ជាប្រភេទដីល្បប់-ខ្សាច់ ជាដីមានជីជាតិល្អ លិចទឹករាល់ឆ្នាំ និងមានរស់ជាតិជូរ

-ស្រទាប់ដីកសិកម្មមានជំរៅពី ១០-២០ ស.ម pH = ៦,៥-៧,៥

-មានផ្ទៃដីចំនួន ២២២.៩០០ ហ.ត អាចដាំដុះបាន ១១១.៩០០ ហ.ត

-ដាំដំណាំស្រូវ ទិន្នផល ០.៤ ត/ហ.ត

-តំឡើងទិន្នផលស្រូវដោយប្រើ :

-ចាត់ចែងទឹកឱ្យបានត្រឹមត្រូវ

-ជីស្រស់ ជីហ្វូស្វាត និង ជីប៉ូតាស

-គេអាចដាំដំណាំ ថ្នាំជក់ ឪឡឹក សណ្តែក........

**១១_ដីជូរ** (Acid Sulfate Soils ) :

-ជាប្រភេទដីល្បប់-ឥដ្ឋ ជាដីមានជីជាតិល្អ លិចទឹករាល់ឆ្នាំ និងមានរស់ជាតិជូរ

-ស្រទាប់ដីកសិកម្មមានជំរៅពី ១៥-៣៨ ស.ម pH = ៣,០-៥,០

-មានផ្ទៃដីចំនួន ២៧៨,២០០ ហ.ត អាចដាំដុះបាន ១៣៩.១០០ ហ.ត

-ជាដីព្រៃ និង ស្មៅ

-ផ្តល់ជាតិពុលដល់ដំណាំ ត្រូវការសំរេងយកជាតិជូរចេញ

-ដោយអនុវត្តការប្រើប្រាស់ជាតិកំបោរ និង ហ្វូស្វាត

**១២_ដីប្រផេះបាសិក** (Basic lithosols ) :

-ស្រទាប់ដីកសិកម្មមានជំរៅពី ១០-២០ ស.ម pH = ៦,៥-៨,០

-មានផ្ទៃដីចំនួន ៣៤១.៨០០ ហ.ត

-ជាដីព្រៃ គេអាចដាំដុះដោយរានព្រៃឬស្សី

**១៣_ដីប្រផេះអាស៊ីត** (Acid lithosols ) :

-ជាប្រភេទដីខ្សាច់-ល្បប់ ទៅ ឥដ្ឋ

-ស្រទាប់ដីកសិកម្មមានជំរៅពី ៥-៣០ ស.ម pH = ៤,៥-៦,៥

-មានផ្ទៃដីចំនួន ៤.៥២៧.១០០ ហ.ត

-ជាព្រៃស្រោង មាននៅតំបន់ខ្ពង់រាប

-ជាប្រភេទដីល្បប់-ខ្សាច់ ជាដីមានជីជាតិល្អ លិចទឹករាល់ឆ្នាំ និងមានរស់ជាតិជូរ

-ស្រទាប់ដីកសិកម្មមានជំរៅពី ១០-២០ ស.ម pH = ៦,៥-៧,៥

-មានផ្ទៃដីចំនួន ២២២.៩០០ ហ.ត អាចដាំដុះបាន ១១១.៩០០ ហ.ត

-ដាំដំណាំស្រូវ ទិន្នផល ០,៤ ត/ហ.ត

-តំឡើងទិន្នផលស្រូវដោយប្រើ :

  -ចាត់ចែងទឹកឱ្យបានត្រឹមត្រូវ

  -ជីស្រស់ ជីហ្វូស្វាត និង ជីប៉ូតាស

-គេអាចដាំដំណាំ ថ្នាំជក់ ឪឡឹក សណ្តែក........

**១១-ដីជូរ** (Acid Sulfate Soils) :

-ជាប្រភេទដីល្បប់-ឥដ្ឋ ជាដីមានជីជាតិល្អ លិចទឹករាល់ឆ្នាំ និងមានរស់ជាតិជូរ

-ស្រទាប់ដីកសិកម្មមានជំរៅពី ១៥-៣៨ ស.ម pH = ៣,០-៥,០

-មានផ្ទៃដីចំនួន ២៧៨,២០០ ហ.ត អាចដាំដុះបាន ១៣៩.១០០ ហ.ត

-ជាដីព្រៃ និង ស្មៅ

-ផ្តល់ជាតិពុលដល់ដំណាំ ត្រូវការសំរេងយកជាតិជូរចេញ

-ដោយអនុវត្តការប្រើប្រាស់ជាតិកំបោរ និង ហ្វូស្វាត

**១២-ដីប្រផេះបាសិក** (Basic lithosols) :

-ស្រទាប់ដីកសិកម្មមានជំរៅពី ១០-២០ ស.ម pH = ៦,៥-៨,០

-មានផ្ទៃដីចំនួន ៣៤១.៨០០ ហ.ត

-ជាដីព្រៃ គេអាចដាំដុះដោយរានព្រៃឬស្សី

**១៣-ដីប្រផេះអាស៊ីត** (Acid lithosols) :

-ជាប្រភេទដីខ្សាច់-ល្បប់ ទៅ ឥដ្ឋ

-ស្រទាប់ដីកសិកម្មមានជំរៅពី ៥-៣០ ស.ម pH = ៤,៥-៦,៥

-មានផ្ទៃដីចំនួន ៤.៥២៧.១០០ ហ.ត

-ជាព្រៃស្រោង មាននៅតំបន់ខ្ពង់រាប

**១៤. ដីឥដ្ឋលាយគ្រួស** (Planthide podzols ) :

-ជាប្រភេទដីល្បប់-ខ្សាច់ ទៅ ខ្សាច់-ល្បប់

-ស្រទាប់ដីកសិកម្មមានជំរៅពី ២០-៣០ ស.ម pH = ៤,២-៥,៨

-មានផ្ទៃដីចំនួន ១.៧១៤.៨០០ ហ.ត អាចដាំដុះបាន ៨៥.៧០០ ហ.ត

-ព្រៃស្រោង និង វាលស្មៅ

**១៥. ដីពតសលក្រហមលឿង** (Red-Yellow Podzols ) :

-ជាប្រភេទដីល្បប់-ឥដ្ឋ ជាដីមានជីជាតិល្អ លិចទឹករាល់ឆ្នាំ និងមានរស់ជាតិជូរ

-ស្រទាប់ដីកសិកម្មមានជំរៅពី ១០-២០ ស.ម pH = ៤,៥-៦,៥

-មានផ្ទៃដីចំនួន ១.៧០៦.៤០០ ហ.ត អាចដាំដុះបាន ១.០២៣.៨០០ ហ.ត

-ដាំដំណាំស្រូវប្រដេញទឹក ទិន្នផល ១,០-១,២ ត/ហ.ត

-តំឡើងទិន្នផលស្រូវដោយប្រើ :

-ចាត់ចែងទឹកឱ្យបានត្រឹមត្រូវ

-ជីស្រស់ ជីហ្វូស្វាត និង ជីប៉ូតាស

-មិនត្រូវប្រើប្រាស់ជីដែលមានអ៊ីយ៉ុង $SO_4^{-2}$

-គេអាចដាំដំណាំ ថ្នាំជក់ ឪឡឹក សណ្ដែក........

**១៦. ដីជាំទឹកដែលមានប្រភពដើមចេញពីគ្រួស** (Plinthitic hydromorphics )

ស្រទាប់ដីកសិកម្មមានជំរៅពី ១០-៤០ សម. pH ពី ៤,០ ទៅ ៥,០ និង ជាប្រភេទដីល្បប់ ទៅ ឥដ្ឋ និងមានផ្ទៃដីចំនួន ១២៧.៥០០ ហ.ត ។ ជាប្រភេទដី ដែលមានដុះ ព្រៃក្រាស់ចំរុះ ។ ត្រូវបន្តការពារព្រៃធម្មជាតិ និងប្រុងប្រយ័ត្នការពារកុំឱ្យភ្លើងឆេះព្រៃ ។

# ល្បាយ Bordeaux

Bordeaux Mixture ត្រូវបានគេប្រើជាដំបូងបង្អស់នៅប្រទេសបារាំង ក្នុងការការពារទល់នឹងជំងឺ Downy Mildew លើទំពាំងបាយជូរ ។

ថ្វីត្បិតតែវាជាថ្នាំកសិកម្ម ដែលមានអំពើក្នុងការកំចាត់ផ្សិតដែលជាភ្នាក់ងារជំងឺដំណាំ ក៏ប៉ុន្តែអំពើរបស់វាក៏អាចបណ្តេញសត្វល្អិតចង្រៃផងដែរ ។

Bordeaux Mixture ត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយលើដំណាំបន្លែ ដំណាំហូបផ្លែ ដំណាំកាការ ដំណាំកាហ្វេ ដំណាំក្រូច និង ទំពាំងបាយជូរ ។

Bordeaux Mixture ជាថ្នាំសំលាប់ផ្សិតដែលមានសុវត្ថិភាពក្នុងការប្រើប្រាស់ និងមានកំរិតពុលតិចបំផុតចំពោះសត្វឈាមក្តៅ ។

ការរៀបចំលាយបានត្រឹមត្រូវនៃ Bordeaux Mixture អាចទទួលបាននូវផលជាទីពេញចិត្តក្នុងការកំចាត់ផ្សិតដែលជាភ្នាក់ងារជំងឺ និង ជៀសវាងបាននូវការពុលដំណាំ ។

ប្រសិទ្ធិភាពរបស់វាក្រោយពីបាញ់ការពារ គឺ :

-ដំណាំភាគច្រើន ១៥ ថ្ងៃ

-ដំណាំប៉េងប៉ោះ ៨ ថ្ងៃ

-ដំណាំត្រសក់ ៥ ថ្ងៃ

ដំណើរការលាយ Bordeaux Mixture

Copper sulfat ($CuSO_4$) ជាធាតុសកម្មនៃ Bordeaux Mixture ហើយដែលធាតុសកម្មនេះត្រូវខូចទ្រង់ទ្រាយ និង ក្លាយជាអ៊ីយ៉ុង Cu នៅពេលប៉ះនឹងសំណើម ។ ល្បាយ Bordeaux បានទទួល ពីការលាយសាច់ជូរខៀវ (Blue Vitriol) ជាមួយនឹងកំបោរ (CaO ) នៅក្នុងមជ្ឈដ្ឋានបាស ។

ការលាយល្បាយ Bordeaux គេត្រូវការបរិមាណដូចគ្នានៃធាតុទាំងពីរ ($CuSO_4$ + CaO) ។

១ Kg $CuSO_4$ + ១ Kg CaO + ១00 L $H_2O$

ការរៀបចំល្បាយ Bordeaux ត្រូវធ្វើឡើងភ្លាមៗនៅពេលប្រើប្រាស់ដោយប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៏ដូចតទៅ :

-ការលាយសាច់ជូរខៀវត្រូវធ្វើឡើងក្នុងធុងដែលមិនមែនជាលោហៈ

-កំហាប់ Bordeaux Mixture ត្រូវកំនត់ដោយបរិមាណសាច់ជូរខៀវ

-ជៀសវាងការថែមទឹកនៅពេលលាយ Bordeaux Mixture រហូតដល់កំរិតទាបជ្រុលជាងកំហាប់ដែលចង់បាន ក្នុងករណីនេះបណ្តាលអោយ ល្បាយ មានកករអណ្តែត Suspension ។

-យកសាច់ជូរខៀវមកដាក់ឱ្យរលាយនៅក្នុងទឹកក្តៅ រួចទុកឱ្យត្រជាក់

-ក្នុងការរៀបចំទឹកកំបោរល្អក់ ត្រូវប្រើប្រាស់កំបោររស់ ដែលមានគុណភាពខ្ពស់ ។ បរិមាណកំបោរត្រូវស្មើនឹងបរិមាណសាច់ជូរខៀវ ។ ក្នុងការលាយទឹកកំបោរដំបូងត្រូវចាក់ទឹកបន្តិចចូលទៅក្នុងម្សៅកំបោររស់ រួចកូរវាឱ្យសព្វ រហូតមានសភាពដូចទឹកដោះគោខាប់ បន្ទាប់មកទៀតត្រូវចាក់ ទឹកដែលនៅសល់បន្ថែម

-ការលាយល្បាយទាំងពីរ ដោយចាក់បង្ហូរល្បាយសាច់ជូរខៀវបន្តិចម្តង ៗ ចូលទៅក្នុងល្បាយទឹកកំបោរព្រមទាំងកូរជាប់ជានិច្ច ។

# វិធីសាស្ត្រគ្រប់គ្រងក្រោយពេលប្រមូលផល

## ផ្កាចន្ទ

### ១_ការប្រមូលផល :

ដើម្បីប្រមូលផលផ្កាចន្ទអោយបានត្រឹមត្រូវ យើងគួរត្រូវយកចិត្តទុកដាក់លើកត្តាមួយចំនួនដូចខាងក្រោម :

-សង្កេតទងផ្កាចេញកញ្ចុំអស់ ហើយមានពកស១ ច្រើន ( ការកាត់របៀបនេះសំរាប់លក់ជាទង )

-អាចកាត់បាននៅពេលគេសង្កេតឃើញកញ្ចុំនៃផ្ការីកប្រមាណ ២០-៣០ ភាគរយ ( ការកាត់របៀបនេះ សំរាប់ យកទៅចងជាមួយផ្កាផ្សេងទៀត

-គួរប្រមូលផលបាននៅពេលព្រឹកចាប់ពីម៉ោង ៨-១០ និង ការប្រមូលផលនៅពេលល្ងាចចាប់ពីម៉ោង ៣-៥ ។ វាជាពេលវេលាមួយល្អសំរាប់ផ្កាចន្ទ ព្រោះផ្កាមានសភាពរឹងមាំល្អ ស្រស់ ទឹកសន្សើមដែលអាចធ្វើអោយផ្កា មិនអាចរលួយបាន

-ពេលប្រមូលផល យើងត្រូវជ្រើសរើសយកកាំបិតចុងស្រួចមុតល្អ ដោយកាត់ធ្វើយ៉ាងណាប្រុងប្រយ័ត្នបំផុត ដើម្បីកុំអោយខូចគល់ផ្កា ។ កាត់ជាចំណិតត្រសក់ ហើយទុកទងអោយបានវែង ដើម្បីតុកបានយូរ និងអាចធ្វើការ កាត់តំរឹម បានសមស្របតាមសេចក្តីត្រូវការ ។ នៅពេលកាត់ធ្វើយ៉ាងណាកុំអោយប៉ះពាល់ដល់កូនទងតូច១ផ្សេង ទៀត និង ធ្វើអោយដើមមេមានដំបៅ ។

-អាចប្រមូលផលនៅពេលមានអាកាសធាតុស្ងួត ប៉ុន្តែមិនត្រូវប៉ះពាល់ផ្ទាល់កំដៅព្រះអាទិត្យទេ

-ជំងឺផ្សេង១ ជាពិសេសផ្សិតអាចកើតមានឡើងយ៉ាងឆាប់រហ័ស នៅពេលដែលយើងប្រមូលផលភ្លាម១ បន្ទាប់ពី ភ្លៀងធ្លាក់

### ២_ការតំរឹម និង ការសំអាត

ក្រោយពីប្រមូលផលរួច ដើម្បីអោយផ្កាមានសភាពល្អ យើងធ្វើការសំអាត និងតំរឹមដូចតទៅ :

-ត្រូវដឹកជញ្ជូនដាក់ក្នុងម្លប់ត្រជាក់ភ្លាម១ ជៀសវាងកុំអោយស្វិតស្រពោនទាន់

-ការតំរឹមធ្វើឡើងជាពីប្រភេទគឺ :

-លេខ ១ ទុកប្រវែង ៧-៨ តឹក

-លេខ ២ ទុកប្រវែង ៥ តឹក

ការកាត់តំរឹមយើងយកវាទៅតំរៀបលើដុំឈើ ដើម្បីកាត់វាកុំអោយមានបែកទង ដែលជាហេតុនាំអោយងាយ ស្អុយរលួយ

-យើងត្រូវបេះស្លឹកដែលខូចចោល ឬ ស្លឹកមានស្នាមសត្វបំផ្លាញ ដើម្បីការពារមេរោគឆ្លង

-ការកាត់តំរឹម និង ការសំអាតនេះធ្វើឡើងនៅក្រោមម្លប់ត្រជាក់ ឬ ក្រោមផ្ទះ

### ៣-ការជ្រើសរើស :

ផ្កាចន្ទជាប្រភេទផ្កាមេ យើងអាចប្រើវាតែឯកឯងក៏បាន ឬ ជាចំរុះជាមួយផ្កាផ្សេងទៀតក៏បាន។ ដូច្នេះការជ្រើសរើសផ្កាចន្ទ គឺមានបីប្រភេទ :

ផ្កាចន្ទដែលចាត់ទុកជាប្រភេទដូចខាងក្រោម :

-លេខ១ គឺមានដងដើមចាប់ពី ៧០ ស.ម ឡើងទៅ កញ្ចុំផ្កាធំល្អ ហើយរីកមិនលើសពី ២០ ភាគរយ ។

-លេខ២ គឺមានដើមដងចន្លោះពី ៥០-៧០ ស.ម មានកញ្ចុំផ្កាល្អ និង រីកមិនលើសពី ៣០ ភាគរយ

-ក្រៅពីនេះយើងចាត់ទុកជាប្រភេទផ្កាលេខ ៣ ដែលអាចយកទៅចង លក់ជាមួយផ្កាផ្សេងទៀត ។

### ៤-ការវេចខ្ចប់ និង ដឹកជញ្ជូន :

ការវេចខ្ចប់ គឺជាការងារចាំបាច់ដែលយើងត្រូវធ្វើ ក្នុងនោះមាន :

-ការចងជាបាច់ៗ ( ដែលមានចំនួន ៥ ដុំ ស្មើនឹង ១០០ ដើម តាមប្រភេទលេខ ១ និង លេខ ២

-គេអាចចងវាដោយខ្សែកំប្លោក ឬ ខ្សែចេក

-ក្រោយមក តំរៀបផ្កានោះដាក់ក្នុងកញ្ជ្រោ ដើម្បីដឹកជញ្ជូនទៅផ្សារ ។ ក្នុងការតំរៀបយើងគួរតំរៀបបញ្ឈរ ប្រសើរជាងផ្តេក ដោយរក្សាទុកអោយមានចន្លោះខ្យល់ចេញចូលបានល្អផង ។ ការវេចខ្ចប់នេះយើងគួរប្រើស្លឹកចេក ឬស្លឹកឈូកស្រស់មកទ្រាប់កញ្ជ្រោ ដែលមានកំរាស់ក្រាស់ល្មម និងមានហ៊ុំព័ទ្ធសងខាង ហើយលើដុំផ្កានិមួយៗក៏ហ៊ុំព័ទ្ធផងដែរ ។

-ដាក់ផ្តេកផ្កានៅក្នុងកញ្ជ្រោប្រហែលកំរាស់ ២០ ស.ម

-ការដឹកជញ្ជូន យើងត្រូវថ្នមបំផុត ជៀសវាងការប៉ះទង្គិចខ្លាំងដែលនាំអោយខូចកញ្ចុំផ្កា

### ៥-ការស្តុកទុក :

ការស្តុកទុករបស់ផ្កាចន្ទ ជាការចាំបាច់មួយដោយយើងយកវាទៅទុកក្នុងបាសាំងទឹក ពាង ប៉ោត ចានដែក ដែលដាក់ផ្កាក្នុងទឹកនោះជំរៅ ២-៤ ម.ម ការពារកុំអោយផ្កាស្រពោន ។ យើងគួរដាក់វានៅកន្លែងម្លប់ត្រជាក់មានខ្យល់ចេញចូលល្អ ។ នៅពេលទុកបានយូរថ្ងៃ ត្រូវប្តូរទឹកចេញ កុំអោយស្អុយទឹកនាំអោយងាយរលួយ ហើយត្រូវចិតជាចំណិតត្រសក់ដដែល ដើម្បីអោយវាអាចស្រូបទឹកបាន ។ ការធ្វើរបៀបនេះ យើងអាចរក្សាទុករយៈពេល ៧ ថ្ងៃ ដោយពុំខូចគុណភាពឡើយ ។

រីឯការដឹកជញ្ជូន គឺយកធុងផ្កាកំពុងក្លាសេ្សទៅដាក់លើម៉ូតូ រ៉ឺម៉ក ឬ ឡានតែម្តង ។ តែធ្វើយ៉ាងណាដឹកនៅពេលត្រជាក់ ដើម្បីកុំអោយទឹកកកឆាប់រលាយ នាំអោយប៉ះពាល់ដល់ផ្កា ។

## ៥_ការរក្សាទុកផ្កាម្លិះ :

ក្នុងការថែរក្សាទុកផ្កាម្លិះអោយបានយូរយើងត្រូវ :

-ចាក់ជាភួង រួចយកទៅក្លាស្សេក្នុងទឹកកក' ការធ្វើរបៀបនេះ អាចរក្សាទុកបានពី ៤-៦ ថ្ងៃ តែមានជាំ ឬ រលួយខ្លះ ឯកុណភាពផ្កានៅល្អ អាចលក់បាន

-ប្រើស្បោងប្លាស្ទិកធម្មតា ដែលមានចំណុះពីកន្លះគីឡូក្រាម ទៅ ២ គីឡូក្រាម ច្រកផ្កាម្លិះខ្ចប់អោយជិតល្អ រួចកាស្សេក្នុងធុងទឹកកក ធ្វើយ៉ាងណាកុំអោយជ្រាបទឹកចូលក្នុងស្បោង ។ ធ្វើរបៀបនេះ យើងអាចរក្សាទុកបានរយៈពេលជិត ២ អាទិត្យ ដោយមានក្លិន និង គុណភាពល្អប្រសើរ ។

# ស្ពៃចង្កឹះ

## ១_ការប្រមូលផល

ដើម្បីអោយការប្រមូលផលមានដំណើរការល្អ និងកាត់បន្ថយការបាត់បង់ យើងគួគប្បីងនុវត្តដូចតទៅ :

-យើងអាចប្រមូលផលស្ពៃចង្កឹះនេះបាន លុះត្រាតែវា" ដើម ធាង មានម្សៅ" ឬដើមខ្លះមានក្របួចផ្កា

-ការប្រមូលផលភាគច្រើន យើងធ្វើឡើងនៅពេលព្រឹកស្រស់ទឹកសន្សើម ចាប់ពីម៉ោង ៨-១០ ព្រឹក និង ពីម៉ោង ២-៤ រសៀល ពីព្រោះពេលមានសីតុណ្ហភាពត្រជាក់ល្មម ដែលអាចបង្កលក្ខណ:អោយស្ពៃស្រពាប់តាមធម្មជាតិបាន ។

-ការប្រមូលផលនេះ យើងត្រូវយកកូនកាំបិតស្លាមុត ឬកូនកាំបិតចុងស្រួចមកកាត់ត្រឹមលើដី

-ពេលចាប់ផ្តើមកាត់ត្រូវយកដៃក្តោប ឬក្រសោបធាងថ្មម១ ហើយទាញតិច១ ផ្តេកគល់បន្តិចទើបកាត់តែម្តង

-មិនគួរកាត់នៅពេលមានភ្លៀង ហើយមិនត្រូវដាក់ស្ពៃនៅក្រោមពន្លឺថ្ងៃទេ

## ២_ការតំរែម ឬ សំអាត

ការសំអាតឬតំរែមនេះ វាជាការងារមួយចាំបាច់បំផុត ដើម្បីកាត់បន្ថយការឆ្លងមេរោគ ធ្វើអោយមានសោភ័ណភាព និង ទាក់ទាញផ្នែកអ្នកទិញ ឬ អតិថិជន ។ ក្នុងការងារនេះ ការសំអាតស្ពៃចង្កឹះមានលក្ខណ:ដូចខាងក្រោម :

-គេធ្វើឡើងភ្លាម១ នៅពេលកំពុងកាត់តែម្តង ពោលគឺយើងកាត់បណ្តើរ ដោយបេះធាងណាដែលស្អុយរលួយចេញ ពិសេសធាងក្រោមចាស់១ និង ធាងណាដែលមានស្នាមសត្វបំផ្លាញ

-យើងមិនត្រូវលាងទឹកស្ពៃចង្កឹះទេ ពិព្រោះវានឹងឆាប់រងនូវការរលួយ ដោយសារជាតិទឹកក្នុងដើមវាច្រើន

៣-ការជ្រើសរើស :

ការជ្រើសរើស ក៏អាចធ្វើអោយបន្លែយើងមានតំលៃខ្ពស់ផងដែរ  គឺយើងជ្រើសរើសវាតាមទំហំលេខ ១ លេខ ២ និងលេខ ៣ ដើម្បីងាយស្រួលក្នុងការតំរៀប និងលក់ផងដែរ

## ៤-ការវេចខ្ចប់ និង ដឹកជញ្ជូន

ក្រោយពីការសំអាត ឬ តំរឹម និងជ្រើសរើសរួចយើងគួរធ្វើការតំរៀបវាជាដុំៗ ដែលក្នុងនោះមាន :

-តំរៀបជាដុំពី ១-១,៥ គ.ក្រ ក្នុងកញ្ជ្រែឬស្សី ឬ ជាលដែក ជាស្រទាប់ៗ ដែលក្បាល ឬគល់ចេញមកខាង ។ នៅក្នុងកញ្ជ្រែ ឬ ជាល យើងត្រូវតំរៀបស្លឹកចេកបាតក្រោម  ដែលមានកំរាស់ពី ២-៣ ស.ម ហើយហ៊ុំព័ទ្ធសងខាងផង ឬក៏អាចយកបាវមកហ៊ុំព័ទ្ធជមនួសស្លឹកចេក

-នៅក្នុងកញ្ជ្រែ ឬជាលយើងអាចតំរៀបបាន ១០០-១២០ គ.ក្រ  តែមិនត្រូវសង្កត់លើបន្ថែមនោះទេ    ជាហេតុនាំអោយវាបាក់បែក ឬ បណ្តាលអោយរលួយបាន  ហើយដាក់បន្លែអោយត្រឹមរឹមកញ្ជ្រែបានហើយ

-ពេលរៀបដាក់ក្នុងជាល ឬ កញ្ជ្រែហើយ យើងលើកវាដាក់លើម៉ូតូ រ៉ឺម៉ក  ឬឡាន  ហើយយើងមិនត្រូវដាក់កញ្ជ្រែគរលើគ្នា ឬ អង្គុយលើទេ ដែលនាំអោយពេលធ្វើដំណើរ រលាក់សង្កត់ខ្លាំងលើបន្លែ ជាហេតុធ្វើអោយបាក់  ជាំ។

## ៥-ការស្តុកទុក

-ការស្តុកទុកគឺមិនចាំបាច់កាត់ឫសចេញទេ  ព្រោះវាអាចស្តុកទុកបានយូរជាងការកាត់ឫស  ដោយសារវាមិនស្ងួតបញ្ចេញទឹកខ្លាំង

ការស្តុកទុកវាជាការចាំបាច់មួយ ដែលយើងគួរតែធ្វើ  ការងារនេះត្រូវបែងចែកជា ២ គឺការស្តុកទុកនៅលើរងពេលកាត់ភ្លាមដើម្បីអោយស្រពោន និងម្យ៉ាងទៀតស្តុកទុកក្រោយពេលប្រមូលផលស្រេចបាច់ហើយ ។

ការស្តុកទុកក្រោយពេលប្រមូលផល យើងធ្វើឡើងដោយទុកពង្រាយនៅលើគ្រែ ដែលតំរៀបអោយស្តើងល្មមកុំអោយហាប់ពេក  ដោយទុកអោយខ្យល់ចេញចូល ហើយមិនត្រូវប៉ះវាទេ  តែករណីយូរថ្ងៃ  គេប្តូរទីតាំង ឬរែបវាបាន ។ ការទុករបៀបនេះ ស្ពៃចង្កឹះអាចបានត្រឹមតែ ១-២ ថ្ងៃប៉ុណ្ណោះ ។ ចំពោះស្ពៃចង្កឹះដែលមិនប្រើជីគីមី  យើងអាចរក្សាទុកវាបានរហូតដល់ ៦-៨ ថ្ងៃ ដោយប្រើបច្ចេកទេសរបៀបនេះ ។

# ស្ពៃក្តោប

## ១-ការប្រមូលផល

-ជាទូទៅ យើងប្រមូលស្ពៃក្តោបដោយសំគាល់ទៅលើអាយុរបស់វា    គឺចាប់ពី ៣ ទៅ ៣ ខែកន្លះ បន្ទាប់ពីដាក់គ្រាប់ដល់ដី

-បន្ទាប់ពិនេះ គឺការពិនិត្យទៅលើលក្ខណៈក្តោបរបស់ស្ពៃ ដូចជាយកដៃច្របាច់ទៅលើវា បើរឹងល្អមានន័យថា ស្ពៃពេញវ័យអាចប្រមូលផលបាន ឬ សំគាល់ទៅលើចុងស្លឹកស្រទាប់ក្រៅរបស់វាមូរ

-ពេលប្រមូលផល គឺធ្វើឡើងនៅពេលល្ងាចត្រជាក់ល្អពីម៉ោង ៣-៤ ដើម្បីអោយទឹកសន្សើមស្រស់ល្អ

-ការប្រមូលផលត្រូវយកកូនកាំបិតចុងស្រួច ដែលមុតល្អកាត់វាដោយទាញក្តោបរាងផ្អែកបន្តិច រួចទើបកាត់

-ការប្រមូលផលត្រូវធ្វើឡើងនៅពេលមានអាកាសធាតុស្ងួតល្អ ។ កាលណាយើងប្រមូលផលនៅពេលភ្លៀង ឬ បន្ទាប់ពិភ្លៀងភ្លាម១ នោះធ្វើអោយមេរោគងាយបង្កជំងឺ អោយស្ពៃក្តោបឆាប់រលួយ

## ២-ការតំរឹម និង សំអាត

-ក្រោយពីកាត់រួច យើងពុំចាំបាច់បកស្រទាប់ក្រៅចេញទេ គឺគ្រាន់តែតំរឹមអោយស្អាត ហើយលាបកំបោរភ្លាម១ ឬ សាច់ជុរនៅមុខកាត់ ដើម្បីការពារការចេញជ័រច្រើន ឬ ឆ្លងជំងឺផ្សេង១ ។ បន្ទាប់មកយកវាទៅដាក់ ក្នុងម្លប់ថ្មម១ ហើយមិនដាក់គរលើគ្នាទេ ជៀសវាងកុំអោយជាំ

-ការសំអាត គឺយើងគ្រាន់តែកាត់សំបកបន្តិចបន្តួចបានហើយ រួចប្រញាប់យកវាទៅដាក់នៅកន្លែងម្លប់ត្រជាក់ ដើម្បីកុំអោយហួតជាតិទឹក ស្វិតស្រពោនបាត់បង់ទំងន់

## ៣-ការវេចខ្ចប់ និង ដឹកជញ្ជូន

-ដើម្បីអោយការវេចខ្ចប់ និង ដឹកជញ្ជូនបានល្អ មិនបាត់បង់យើងអាចប្រើចំបើង ក្រដាស បាវ ស្លឹកចេក ឬ ស្លឹកឈុកសំរាប់ធ្វើជាទ្រនាប់ ដើម្បីកាត់បន្ថយការប៉ះទង្គិច

-ឯការដឹកជញ្ជូន គួរដាក់តាមថ្នាក់១ ជៀសវាងការដាក់គរលើគ្នា

-បើសិនអាចធ្វើបាន យើងអាចយកក្រដាសកាសែតមកហ៊ុំលើក្តោបនិមួយ១ តែម្តងទើបដាក់បញ្ចូលក្នុងកញ្ចោ

-ជៀសវាងការបកធាងស្រទាប់ក្រៅរបស់វាមុនពេលដាក់លក់លើស្តង់

-ពេលដឹកជញ្ជូន ត្រូវរក្សាអោយមានគំរបជានិច្ចដើម្បីការពារកំដៅ និងធូលី ។

## ៤-ការស្តុកទុក

យើងអាចស្តុកស្ពៃក្តោបដោយធ្វើការរុំក្រដាសកាសែត ហើយយកវាទៅដាក់ ក្នុងធុងត្រជាក់/ពាងធ្វើពីដីគ្រប ក្រណាត់សើម ហើយប្រោះទឹក ១ ថ្ងៃ ២ ដង ( ព្រឹក-ល្ងាច) លើក្រណាត់នោះ នៅពេលវាស្ងួត ។ ជាលទ្ធផលគឺយើងរក្សាទុកបានយូររហូតដល់ ១៦ ថ្ងៃ ដោយពុំមានស្រកទំងន់ឡើយ

## ផ្លែត្រប់

### ១-ការប្រមូលផល

ដើម្បីអោយការប្រមូលផលត្រប់បានល្អ យើងគួរអនុវត្តនូវចំណុចមួយចំនួនដូចខាងក្រោម :

-ត្រូវបេះផ្លែត្រប់ណាដែលមានទំហំធំល្មម ពោលគឺមិនខ្ចីពេក មិនចាស់ពេក

-យើងត្រូវកាត់សណ្តង់ផ្លែ ឬ ទងដោយកូនកាំបិត ឬ កន្ត្រៃមុតល្អ

-ទុកសណ្តង់ប្រវែងប្រហែលមួយចង្អុលដៃ ឬ ៤-៥ ធីង ដើម្បីកុំអោយជ័រចេញច្រើនពីផ្លែ ឬ រលួយក្បាលផ្លែ

-យើងបេះ ឬកាត់នៅម៉ោង ៨-១១ ព្រឹក ឬ ម៉ោង ២-៥ ល្ងាច ជាពេលដែលស្ងួតសំណើម ហើយពេលថ្ងៃក្តៅខ្លាំងត្រូវជញ្ជូនចូលម្លប់ភ្លាមៗ បន្ទាប់ពីប្រមូលផល

-យើងកាត់ទងសណ្តង់កុំអោយបែក ជាហេតុធ្វើអោយផ្លែ និង ដើមអន់ ហើយវាអាចឆ្លងមេរោគដល់ផ្ការបស់វាទៀត

### ២-ការសំអាត និង ជ្រើសរើស

ក្រោយពីប្រមូលផលរួច យើងគួរធ្វើការសំអាត និង ជ្រើសរើសជាចាំបាច់ ដើម្បីធ្វើអោយផលិតផលរបស់យើងមានសោភ័ណភាព ចំនុចដែលត្រូវធ្វើ :

-ជ្រើសរើសផ្លែណាដែលស្អុយរលួយចេញ ដើម្បីកុំអោយវាឆ្លងដល់គេ

-ចិតទងសណ្តង់ចេញខ្លះបើវែងពេក ទុកតែមួយចង្អុលដៃជាការល្អ

-ជ្រើសរើសយកផ្លែមិនប្រក្រតី ដូចជាស្វិត ក្រងិក្រង៉ក់មានស្នាមសត្វល្អិតបំផ្លាញ ក្រិនរឹងជាដើម ។ល។

-ជ្រើសរើសយកផ្លែដែលខ្ចីពេក និង ចាស់ពេកចេញ

-យើងត្រូវលាងទឹកសំអាតដីភក់ដែលប្រឡាក់ចេញ ដោយប្រើប្រាស់ក្រណាត់សើមជូតវាចេញ កាលណាលាងផ្លែត្រប់ដោយប្រើទឹកនោះផ្លែត្រប់នឹងស្រូបទឹក ធ្វើអោយវាទុកមិនបានយូរ

-យើងត្រូវជ្រើសរើសវាដាក់តាមទំហំផ្លែរបស់វា តាមប្រភេទ

-ត្រូវយកក្រណាត់ ឬ បាវសើមគ្របពីលើ ការពារកំដៅថ្ងៃ និង ធូលីដីហុយប្រឡាក់

### ៣-ការវេចខ្ចប់ និង ដឹកជញ្ជូន

ក្រោយពីការសំអាតរួចស្រេចបាច់ យើងគួរទុកផ្លែត្រប់អោយស្រស់ទឹកសិន ទើបយើងធ្វើការវេចខ្ចប់ដើម្បីងាយស្រួលដឹកជញ្ជូនមកកាន់ទីផ្សារ ។ ដើម្បីអោយការងារនេះប្រព្រឹត្តទៅក្នុងដំណើរការល្អ សមស្របនឹងសេចក្តីត្រូវការនោះ យើងត្រូវប្រកាន់ខ្ជាប់ខ្ជួននូវចំនុចដូចខាងក្រោម :

-ត្រូវយកផ្លែត្រប់តំរៀបដាក់ក្នុងកញ្ជ្រោ ឬ ជាល តាមប្រភេទ ដើម្បីងាយស្រួលកំណត់តំលៃ

-កញ្ជ្រោ ឬ ជាលត្រូវទ្រាប់ស្លឹកចេកនៅ បាត និង សងខាងដែលមានកំរាស់ ២-៣ ធីង ការពារការប៉ះទង្គិចដល់ផ្លែ

នាំអោយខូចគុណភាព

-ត្រូវតំរៀបផ្លែត្រប់អោយមានសណ្តាប់ធ្នាប់ល្អ គឺដាក់ក្បាលជល់គ្នា ដើម្បីកុំអោយទងវាជង់គ្នាធ្វើអោយខូចផ្លែ

-ពេលដឹកជញ្ជូនត្រូវដាក់កញ្ជេ ជាល កុំអោយគរលើគ្នា ធ្វើយ៉ាងណាអោយមានជាថ្នាក់ ១ ។

## ៤-ការស្តុកទុក

ការស្តុកទុកផលិតផលត្រប់នេះ គេសង្កេតឃើញមាន :

-ទុកក្នុងមួប់ដើកមឈើ ក្រោមផ្ទះ និងរោងចាំចំការដែលមានអាកាសធាតុត្រជាក់ល្អ

-ត្រូវគ្របក្រណាត់សើម ឬ បាវពីលើបើទុកមួយថ្ងៃឧស្សាហ៍ ប្រោះទឹកថែម

-ម៉្យាងទៀតយើងឧស្សាហ៍ ជ្រលក់ទឹកត្រជាក់ ក្នុង ១-៣ ដង ក្នុងករណីនេះយើងអាចរក្សាត្រប់ទុកបាន ៤-៥ថ្ងៃ

# ខាត់ណា

## ១-ការប្រមូលផល

បន្លែខាត់ណាឈើ គឺជាប្រភេទបន្លែដែលពិបាកគ្រប់គ្រងណាស់ ព្រោះវាស្រួយ និង ងាយរលួយ តែដើម្បីប្រមូលវាអោយបានល្អ ត្រូវយកចិត្តទុកដាក់ដូចជា :

-ការប្រមូលផលខាត់ណាឈើ ធ្វើឡើងក្រោយពីដាំបានរយៈពេលពី ២-២ ខែកន្លះ

-យើងសំគាល់ឃើញដើម និងស្លឹករបស់វាឡើងម្សៅ ឬ ដើមមេមួយៗ ចាប់មានក្របួចផ្កា

-ការប្រមូលផលធ្វើនៅពេលអាកាសធាតុត្រជាក់ ហើយស្ងួតទឹកសន្សើមល្អពីម៉ោង ៩ ព្រឹក ដល់ម៉ោង ៣ ល្ងាច

-នៅពេលកាត់ យើងត្រូវប្រើកូនកាំបិតស្លាតូចៗ ដែលមុតល្អ និង មុខកាត់ស្មើល្អ ដើម្បីកុំអោយពិបាកតំរឹមទៀត

-ជៀសវាងការដាក់ខាត់ណានៅលើដី និងក្រោមកំដៅថ្ងៃ ព្រោះវាងាយធ្វើអោយខាត់ណារលួយ

-ជំងឺ និង ផ្សិតងាយកកើតឡើងយ៉ាងឆាប់រហ័ស នៅពេលដែលយើងកាត់ខាត់ណាបន្ទាប់ពីមានភ្លៀងធ្លាក់ភ្លាមៗ

-មុនពេលកាត់ត្រូវបង្អត់ទឹកវារយៈពេលថ្ងៃ ដើម្បីកុំអោយវាបៀមទឹក ឬស្រូបទឹក ហើយមិនអាចអោយវារក្សាទុកបានយូរទេ ។

## ២-ការសំអាត ឬ តំរឹម

-ការតំរឹម និង សំអាតត្រូវធ្វើឡើងភ្លាមៗ ក្រោយពីកាត់រួច ដោយកាត់ស្លឹកចាស់ៗ ឬ ស្លឹកខូចចោល និង តំរឹមគល់ណាដែលមិនស្មើ

-សំដិលវារយៈពេលពី ២០-៣០ នាទី ដើម្បីអោយវាស្រពាប់បន្តិច

-បន្ទាប់មកជញ្ជូនវាទៅដាក់ក្នុងមួប់ដែលត្រជាក់ល្អ

## ៣_ការជ្រើសរើស

-ក្រោយពីជញ្ជូនវាដាក់មួប់ គឺយើងត្រូវជ្រើសរើសដាក់តាមប្រភេទ

-ធ្វើការតំរៀបជាដុំតូច១ យកល្អកុំរៀបវាច្រើនពេក គឺចាប់មួយរង្វង់ដៃពីរ លើសពីនេះនាំអោយប្រើកំលាំងសង្កត់ លើវាខ្លាំង នៅពេលដែលតំរៀបវាដាក់ក្នុងកញ្ជោ

## ៤_ការវេចខ្ចប់ និង ដឹកជញ្ជូន

-ក្រោយពីបានរៀបជាដុំតូច១ រួចមក យើងអាចតំរៀបចូលទៅក្នុងកញ្ជោ ដោយមានស្លឹកចេកស្រស់ ឬ បាវព័ទ្ធជុំវិញ

-ក្នុងការតំរៀប ធ្វើយ៉ាងណាអោយក្បាលរបស់វាគងលើគ្នាដោយមានគំលាតពី ១-១ តឹកកន្លះ យោងទៅតាមដើមបន្លែតូចឬធំ

-រៀបជាស្រទាប់១ ដោយជៀសវាងការសង្កត់ពីលើវាខ្លាំង ដែលនាំអោយបែកឬជាំខូចគុណភាព និងឆាប់រលួយ

-ក្នុងមួយកញ្ជោមានចំនុះពី ១៨០-២០០ គ.ក្រ បើអាចគួរប្រើចំនុះតិចជាងនេះទើបល្អ

-ការដឹកជញ្ជូន គយរដឹកដោយឡាន ឬ ទុក ដោយមានគ្របដំបូលត្រជាក់ ហើយកុំដាក់កញ្ជោគរលើគ្នា

-រៀបបញ្ចូលក្នុងឡានឬ ទុកដោយថ្នាក់១

## ៥_ការស្តុកទុក

ជាធម្មតាការស្តុកទុកខាត់ណាឈើ មានការលំបាកណាស់ តែតាមរយៈការសាកល្បងកន្លងមក ឃើញថាអាចរក្សាទុករហូតដល់ ៦ ខែ ។ តែការរក្សាទុកនេះ ត្រូវយកចិត្តទុកដាក់លើចំណុចមួយចំនួនដូចជា :

-កាត់វាពេលអាកាសធាតុត្រជាក់ ហើយស្ងួតសន្សើមកាត់ភ្លាមត្រូវលាបសាច់ជូរ ឬកំបោរលើមុខកាត់ភ្លាម ដើម្បីកុំអោយចេញជ័រច្រើនពេក រួចយកវាទៅដាក់ក្នុងរោងស្តុកទុក ឬ ក្រោមផ្ទះ ដោយយកក្រណាត់សើមហ៊ុំចុំវិញ តែមិនអោយប៉ះលើបន្លែឡើយ ។ ក្នុងករណីនេះយកល្អគឺធ្វើយ៉ាងណាអោយក្រណាត់នោះសើមជានិច្ច ។ តាមបទពិសោធន៏កន្លងមក ត្រូវយកចានដែក ឬ ធុងដែលមានទឹកពេញមកដាក់លើធ្នើរ រួចគ្របក្រណាត់ធ្វើរបៀបនេះ គឺទឹកស្រូបចូល ធ្វើអោយក្រណាត់សើមជានិច្ច ដែលអាចធ្វើអោយបន្លែនៅស្រស់ជានិច្ច ។

# ការ៉ុត

## ១_ការប្រមូលផល

ជាទូទៅការ៉ុតមានរយៈពេលលូតលាស់ ៣-៣ ខែកន្លះ នៅរដូវវស្សា បើនៅរដូវប្រាំងអាចមានរយៈពេលដល់ទៅ ៤ ខែ ទើបអាចប្រមូលផលបាន ។

-ការប្រមូលផល ជាដំបូងយើងត្រូវពិនិត្យទៅលើ អាយុកាលនៃការដុះលូតលាស់របស់វា ។ បើដល់អាយុហើយ យើងត្រូវពិនិត្យទៅលើលក្ខណៈដងដើមរបស់វាទៀត ដូចជាស្លឹកទី ១ ឬ ទី ២ ក្បែរគល់ ប្រែពណ៌បៃតងទៅជាពណ៌លឿង គឺយើងអាចប្រមូលផលបាន

-ការប្រមូលផល គឺត្រូវធ្វើឡើងដោយដៃ ចាប់ដកដើមពីក្នុងថ្នាលតែម្តង បើដីថ្នាលនោះផុសល្អ

-ម្យ៉ាងទៀត វិធីល្អបំផុតយើងត្រូវប្រើចបចក់ដែលមានធ្មេញវែងៗ គាស់វាជាមុនសិនទើបប្រមូលតាមក្រោយជាការល្អ ។ ពេលវេលានៃការប្រមូល គឺត្រូវស្ងួតទឹកសន្សើម ឬ គ្មានភ្លៀង ឬក៏ដីសើម ឬស្ងួតពេក

២-ការតំរឹម និង សំអាត

-ការ៉ុតក្រោយពីដករួច គឺមិនត្រូវលាងទឹកទេ ពីព្រោះបើលាងវា នាំអោយឆាប់រលួយ

-ការសំអាត គឺគ្រាន់តែបេះដីណាដែលជាប់ធមពេកនៅលើមើមតែប៉ុណ្ណោះ តែមិនត្រូវអោយជ្រះពេកទេ គឺទុកវាខ្លះដើម្បីការពារសំណើម និង សំបកកុំអោយវារលាក

-កាត់តំរឹម គឺយើងកាត់ ឬសស្វៃវែងៗ ដែលជាប់ដើមរបស់វាចេញ និងការស្លឹករបស់វាដោយទុក ចំងាយពីមើមប្រហែល ១-១,២ ម.ម ។ រួចយកវាទៅជ្រលក់ទឹកកំបោរត្រង់មុខកាត់ ដើម្បីការពារជ្រាបទឹកឬការឆ្លងមេរោគ

## ៣-ការជ្រើសរើស

ក្រោយពីប្រមូលផល និង កាត់ដើម ឬសចេញហើយ យើងត្រូវរៀបវាជា ៣ ផ្នែក គឺផ្នែកទី១ ជ្រើសរើសមើមធំដាក់មុំ និង ទី ២ មើមធំល្មម និង ទី៣ មើមដែលមានខ្នែង

## ៤-ការវេចខ្ចប់ និង ដឹកជញ្ជូន

-ក្រោយពីសំអាត និងជ្រើសរើសរួចមក យើងអាចយកវាទៅតំរៀបក្នុងកញ្ជៅដែលមានទ្រាប់ស្លឹកចេក ឬ ស្លឹករុក្ខជាតិផ្សេងទៀតនៅបាត និង ហ៊ុំព័ទ្ធជុំវិញ

-ក្នុងការដាក់វាទៅក្នុងកញ្ជៅ គួររក្សាវាអោយនៅមានដីខ្លះៗ នៅជាប់មើមរបស់វា បើមិនដូចនេះទេ យើងយកដីខ្សាច់មករោយចន្លោះមើមដែលបានរៀបរួច ដើម្បីរក្សាសំណើម និង កាត់បន្ថយការប៉ះទង្គិច




ត្រីកោណចែកវាយនភាពដីរបស់ **USDA**

| | |
|---|---|
| ឥដ្ឋ (Clay) | ល្បាយ ( Loam) |
| ឥដ្ឋល្បាយ (Silty clay) | ល្បាយល្អារ ( Silt loam) |
| ឥដ្ឋខ្សាច់ (Sandy clay) | ល្បាយម៉ដ្ឋ ( Silt) |
| ល្បាយឥដ្ឋ (Clay loam) | ល្បាយខ្សាច់ ( Sandy loam) |
| ឥដ្ឋល្បាយ (Silty clay loam) | ល្បាយខ្សាច់ (Loamy sand) |
| ល្បាយឥដ្ឋខ្សាច់ (Sandy clay loam) | ខ្សាច់ (Sand) |

## ៩.ការយល់ដឹងពីអ័រម៉ូន

៩.១ សារធាតុជួយជំរុញអោយរុក្ខជាតិលូតលាស់ហើយមាននៅក្នុងរុក្ខជាតិ

ក-Ethylene

ជាសារធាតុម៉្យាងដែល :

- -រុក្ខជាតិចេញផ្កា
- -ដុះលូតលាស់ក្បៀងសារជាថ្មីបានឆាប់រហ័ស
- -មាននៅក្នុងគ្រាប់សំរាប់ជំរុញដល់ការលូតលាស់របស់គ្រាប់
- -ជួយដល់រុក្ខជាតិដែលធ្វើអោយផ្លែឆាប់ទុំ




ខ-Cytokinins

ជំរុញអោយគ្រាប់រុក្ខជាតិដុះលូតលាស់បានល្អហើយមាននៅក្នុងគ្រាប់រុក្ខជាតិតែម្តង

រៀបចំដោយ : លោក ឃួន អៀង ព្រឹទ្ធបុរសរង មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម

## ៩.ការយល់ដឹងពីអ័រម៉ូន (ត)

គ-Hydrogene peroxide

- -ការពារសត្វល្អិតនៅក្នុងគ្រាប់
- -ជួយជំរុញអោយដំណុះ និង
- -ការពារផ្សិតក្នុងគ្រាប់



ឃ-Auxins

- -ជំរុញអោយមានគ្រាប់រុក្ខជាតិល្អ
- -ជួយសំរួលដល់ប្រព័ន្ធសីតុណ្ហភាព

រៀបចំដោយ : លោក ឃួន អៀង ព្រឹទ្ធបុរសរង មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម

## ៩.ការយល់ដឹងពីអ័រម៉ូន (ត)

ង-Thiourea

-ជាសារធាតុមួយដែលជួយដល់ការសំរួលពន្លឺ និង សីតុណ្ហភាពរបស់ដំណុះគ្រាប់

-ជាពិសេសក្នុងកំឡុងដំណើរការរូបសាស្រ្តដែល

កើតឡើងដោយធម្មជាតិនៅពេលទុំ ។



ច-Gibberellins

ជួយដំណុះរបស់គ្រាប់



## ៩.ការយល់ដឹងពីអ័រម៉ូន (ត)

**១០.២ សារធាតុដែលជំរុញអោយរុក្ខជាតិដុះលូតលាស់ខុសពីធម្មតាដែលជាអ័រម៉ូន**

គ្រប់រុក្ខជាតិទាំងអស់មិនមែនសុទ្ធតែ:

-ដុះលូតលាស់

-ចេញផ្លែផ្កាគ្រប់ពេលវេលានោះទេ

-វាចេញផ្កាលុះត្រាតែមានកត្តាជាច្រើនដែលសមស្របសំរាប់ការដុះលូតលាស់របស់វា

ហើយកត្តាទាំងនោះមានដូចជា :

► សីតុណ្ហភាព

► រយះពេលសំរាក ដើម្បីបង្កើតសារធាតុផ្សេងៗ ។

## ៩.ការយល់ដឹងពីអ័រម៉ូន (ត)

បើយើងចង់អោយវាចេញជាផ្កាផ្លែ និង លូតលាស់គ្រប់ពេលវេលា នោះយើងអាចធ្វើបានទៅតាមលក្ខណៈផ្សេង១ដូចជា :

-ការកាត់តែងមែក និង ការកាត់តែងឫស

-ការប្រើប្រាស់សារធាតុអ័រម៉ូនផ្សេង១ដូចជា :

១-Pochlobutrazol (2RS,3RS) – 1 - (4-Chloro Phenyl) – 4 , 4dimethyl – 2 = (1H-1,2,4-triazol-1-yl)

-ជំរុញអោយរុក្ខជាតិចេញផ្កា និង អត្រានៃការចេញផ្កាខ្ពស់

-គេអាចប្រើប្រាស់បានចំពោះដំណាំហូបផ្លែមួយចំនួនដូចជា ធូរេន ស្វាយ មៀន និង ដំណាំស្រូវ ដោយលាយក្នុងកំរិត ១ ភាគរយបាញ់ទៅលើដំណាំតែម្តង ។



## ៩.ការយល់ដឹងពីអ័រម៉ូន (ត)

២-Ethylene

ជួយជំរុញផ្នែកផ្សេង១នៃរុក្ខជាតិអោយដុះលូតលាស់ខុសពីធម្មតាដូចជា :

-ធ្វើអោយផ្លែទុំល្អ ហើយឆាប់ទុំ

-ផ្លាស់ប្តូរការបំភាយចំហាយទឹក

-ការទប់ទល់នឹងការលូតលាស់ដោយការរីកកោសិកា

-ធ្វើអោយត្រួយពន្លកគ្មានដំណេក ធ្វើអោយផ្កាចេញកាន់តែល្អ

-ការធ្វើអោយដំរហូរកាន់តែខ្លាំង

-ការធ្វើអោយកើនឡើងនូវការបំបែងកោសិកានៅក្នុងកោសិកានៃកំប៊ីយ៉ូម

-ធ្វើអោយរុក្ខជាតិចេញផ្កា និង បែកមែកថ្មី

## ៩-ការយល់ដឹងពីអ័រម៉ូន (ត)

ព-Pine Top

-ជាប្រភេទអ័រម៉ូនទឹកដែលជំរុញអោយរុក្ខជាតិចេញផ្កា និង ប្រព័ន្ធឫសដុះបានល្អ ។

-ជាសារធាតុដែលមាន ដែក ម៉ង់កាណែស ម៉ាញ៉េស្យូម ប័រ វិតាមីន B1

-ជាអ័រម៉ូនទឹកដែលយើងលាយក្នុងបរិមាណ១ % ហើយបាញ់ទៅលើរុក្ខជាតិតែម្តង ។

៤-Dat Nong

ជាប្រភេទអ័រម៉ូនទឹកដែលគេប្រើប្រាស់ទៅលើដំណាំសំរាប់អោយវា :

-ចេញផ្កា និង លូតលាស់បានល្អ ជាពិសេសធ្វើអោយផ្លែធំល្អ



## ៩-ការយល់ដឹងពីអ័រម៉ូន (ត)

៥-ATONIK

-ជួយជំរុញអោយចេញត្រួយ និង ស្លឹកបានល្អ

-មុនពេលចេញផ្កា ប្រើអ័រម៉ូននេះលាយទឹកក្នុងបរិមាណ ១ ភាគរយហើយបាញ់ ទៅលើដើមរុក្ខជាតិតែម្តង ។

៦-Ag-GRO

ជាប្រភេទអ័រម៉ូនមួយប្រភេទដែលគេប្រើសំរាប់ផ្សាំរុក្ខជាតិគ្រប់ប្រភេទ ជាពិសេស ដំណាំឈើហូបផ្លែដោយលាប ឬ ត្រាំរយៈពេល ១៥ នាទី ។

៧-Ferti Stars

ជាប្រភេទអ័រម៉ូនជួយជំរុញអោយប្រព័ន្ធឫសដុះបានឆាប់រហ័សដោយគ្រាន់តែ

## ៩.ការយល់ដឹងពីអ័រម៉ូន (ត)

ជ្រលក់ឫស និង សារធាតុអ័រម៉ូននេះ

៨-Gibberellins : Gibberellinn acid, GAO 0,5 %

-ជាអ័រម៉ូនដែលជួយជំរុញ អោយចង្កោមផ្កាលូតលាស់ និង ធ្វើអោយផ្លែគ្មានគ្រាប់

-សារធាតុនេះត្រូវបានគេប្រើប្រាស់វាចំនួន ២ លើក :

- លើកទី ១   ១៤ ថ្ងៃ មុនពេលចេញផ្កា ដោយប្រើបរិមាណ ១០០ ppm
- លើកទី ២ រយៈពេល ១០ ថ្ងៃបន្ទាប់ពីរុក្ខជាតិចេញផ្កា ដើម្បីអោយផ្លែរីកធំ និង មានរសជាតិហើយនឹងធ្វើអោយផ្លែទុំមុនពេលធម្មតា ២៥ ថ្ងៃ ។

រៀបចំដោយ : លោក ឃួន អៀង  គ្រូឧទ្ទេសរង មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម

## ៩.ការយល់ដឹងពីអ័រម៉ូន (ត)

៩-Daminozide Sadh-Nines 8 %

-ជាសារធាតុអ័រម៉ូនដែលគេប្រើដោយបាញ់ទៅលើដើមទាំងមូលក្នុងរយៈពេល :

- ២៥ ថ្ងៃ បន្ទាប់ពីចេញផ្កាបានពេញលេញ
- ឬ រវាងពី ១០-៤៥ ថ្ងៃ មុនពេលប្រមូលផល ។

-គេប្រើវាដើម្បីអោយសំបុររបស់សំបកល្អ និង ការពារផ្លែកុំអោយធ្លាក់ ។

-បរិមាណ ១.០០០-២.០០០ ppm គេប្រើជាពិសេសទៅលើដំណាំប៉ោម

រៀបចំដោយ : លោក ឃួន អៀង  គ្រូឧទ្ទេសរង មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម

## ៩.ការយល់ដឹងពីអ័រម៉ូន (ត)

១០-Banzyladenine : BA3 %

-ជាសារធាតុអ័រម៉ូនទឹកដែលគេប្រើក្នុងកំរិត ៣០០ ppm បាញ់ទៅលើដើមឈើក្មេងដែល ដុះពន្លកបាន ៥០ ស.ម ដើម្បីអោយដុះពន្លកថែមទៀត ។

-ប្រសិន បើគេប្រើកំរិត ១០០ ppm ដើម្បីការពារការជ្រុះផ្ការបស់ទំពាំងបាយជូរ ។

១១-Ethephonethel 10 %

-ជាប្រភេទអ័រម៉ូនដែលគេប្រើលើរុក្ខជាតិច្រើនប្រភេទ ។

-ចំពោះដំណាំហូបផ្លែគេប្រើបរិមាណ ៥០-១០០ ppm ដោយបាញ់ទៅលើដើម ទាំងមូលក្នុងរយៈពេល ១០០ ថ្ងៃ ឬ ច្រើនជាងនេះបន្ទាប់ពីផ្ការីក ដើម្បីធ្វើអោយផ្លែធំ



## ៩.ការយល់ដឹងពីអ័រម៉ូន (ត)

-ចំពោះកៅស៊ូវិញ គឺគេយកវាទៅលាយ និង ប្រេងដូង ដើម្បីធ្វើរំញោចអោយកៅស៊ូចេញ ជ័របានច្រើនដោយលាប នឹងមុខចៀរកៅស៊ូ ។

១២-N-meta-tolyphthalamic acid (TPA)

-ប្រើដើម្បីអោយជាប់ក្តិបបានច្រើន

-ប្រើនៅពេលដែលចង្កោមផ្កាពីរ ឬ បីដំបូងកំពុងចេញផ្កាដោយប្រើក្នុងកំរិត ១ ភាគរយ ។

## ៩-ការយល់ដឹងពីអ័រម៉ូន (ត)

១៣-2,4 Dichlorophenoxy acetic acid (2,4D)

ជាប្រភេទអ័រម៉ូនដែលជំរុញអោយរុក្ខជាតិចេញផ្កា និង មានក្តិបច្រើន ដោយប្រើក្នុងបរិមាណ ៥០ ម.ក្រ បាញ់លើស្លឹក និង ដើម ។

១៤-Ethrel

ជាប្រភេទអ័រម៉ូនទឹកដែលជួយអោយរុក្ខជាតិចេញផ្កា ។ អ័រម៉ូននេះគេប្រើជាពិសេសលើដំណាំចេក ល្ហុងស្វាយ ម្នាស់ ប៉ោម ដោយប្រើក្នុងកំរិត ៥០០ ppm ។



## ៩-ការយល់ដឹងពីអ័រម៉ូន (ត)

១៥-Alar

ជាប្រភេទអ័រម៉ូនម្សៅដែលមានធាតុសកម្ម ៨៥ ភាគរយ គេប្រើទៅលើដំណាំហូបផ្លែដែលធ្វើអោយរុក្ខជាតិចេញផ្កាពេញមួយឆ្នាំ ។

១៦-Amex

ជាប្រភេទអ័រម៉ូនទឹកដែលមានធាតុសកម្ម ៣៦ ភាគរយ ដែលគេប្រើសំរាប់ជំរុញអោយរុក្ខជាតិចេញផ្កាគ្រប់រដូវ ដោយប្រើក្នុងកំរិត ១០០ ppm ។

## ៩.ការយល់ដឹងពីអ័រម៉ូន (ត)

១៧-EA3

ជាប្រភេទគ្រាប់គ្រីស្តាល់ ដែលមានធាតុសកម្ម ១០ ភាគរយដែលគេប្រើសំរាប់ជំរុញអោយរុក្ខជាតិចេញផ្កាដោយប្រើក្នុងកំរិត ១០០ ppm ។

១៨-Rostar

-ជាប្រភេទអ័រម៉ូន ដែលគេប្រើសំរាប់ជំរុញអោយដំណាំឈើហូបផ្លែចេញផ្កា ជាពិសេសផ្កាមៀន

-ដោយប្រើបរិមាណ ១០-២០ ក្រ លាយទឹក ១០ លីត្រ ស្រោចគល់ពីចំណោលកែងរបស់មែក

រៀបចំដោយ : លោក យូន អៀង ព្រឹទ្ធបុរសរង មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម

1 [illegible] Ex ?

2. [illegible] Ex ?

3. [illegible] ?

4 —— [illegible]

5 [illegible] ?

6. [illegible] ?

7 [illegible] ?

8- [illegible] ?

9- [illegible]

10- [illegible]

11- [illegible]

12- [illegible]

13- [illegible]

14- [illegible]

[illegible] /ha [illegible]

BB-15kg, ai?, ai% = 65%, V = 150L/ha

1/ [illegible] ?

- [illegible] 1 = 20 l